ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ៩ លេខ ៤៤ សប្តាហ៍ទី២ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩

រាជកិច្ច

ផ្សាយចេញពី
ទីស្តីការគណៈរដ្ឋមន្ត្រី

តម្លៃ

១ ច្បាប់	៥.០០០ រៀល
១ ខែ	៤០.០០០ រៀល
៣ ខែ	១២០.០០០ រៀល
៦ ខែ	២៤០.០០០ រៀល
១២ ខែ	៤៨០.០០០ រៀល

(ត្រូវបង់តម្លៃជាមុន)

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរ ប្រកាស

ក

មាតិកា

I-ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

១-ព្រះរាជក្រម

១០-៦-២០០៩ -ព្រះរាជក្រម នស/រកម/០៦០៩/០០៧ ស្តីពីការប្រកាសឱ្យប្រើ ច្បាប់ស្តីពីទេសចរណ៍ ៤០២១

២-ព្រះរាជក្រឹត្យ

២៩-៥-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៥០៩/៥៩៧ ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ខេត្ត ព្រះសីហនុ ក្នុងអណត្តិទី ១ ចំនួន ១៥ រូប ៤០៦០

២៩-៥-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៥០៩/៥៩៨ ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាខេត្ត កោះកុង ក្នុងអណត្តិទី ១ ចំនួន ១៣ រូប ៤០៦២

២៩-៥-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៥០៩/៥៩៩ ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាខេត្ត រតនគិរី ក្នុងអណត្តិទី ១ ចំនួន ១៣ រូប ៤០៦៤

២៩-៥-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៥០៩/៦០០ ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាខេត្ត មណ្ឌលគិរី ក្នុងអណត្តិទី ១ ចំនួន ០៩ រូប ៤០៦៦

២៩-៥-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៥០៩/៦០១ ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាខេត្ត កណ្តាល ក្នុង អណត្តិទី ១ ចំនួន ២១ រូប ៤០៦៨

២៩-៥-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៥០៩/៦០២ ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាខេត្ត កំពង់ស្ពឺ ក្នុងអណត្តិទី ១ ចំនួន ១៧ រូប ៤០៧០

២៩-៥-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៥០៩/៦០៣ ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាខេត្ត ឧត្តរមានជ័យ ក្នុងអណត្តិទី ១ ចំនួន ១៣ រូប ៤០៧២

២៩-៥-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៥០៩/៦០៤ ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាខេត្ត ព្រះវិហារ ក្នុងអណត្តិទី ១ ចំនួន ១៣ រូប ៤០៧៤

២៩-៥-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៥០៩/៦០៥ ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាខេត្ត ប៉ៃលិន ក្នុងអណត្តិទី ១ ចំនួន ០៩ រូប ៤០៧៦

២៩-៥-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៥០៩/៦០៦ ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាខេត្ត កែប ក្នុងអណត្តិទី ១ ចំនួន ០៩ រូប ៤០៧៨

៣០-៥-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៥០៩/៦០៧ ស្តីពីការផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាល ជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ជូនមន្ត្រីរាជការចំនួន ១៤ រូប ទៅតាមលំដាប់ថ្នាក់ន្តរស័ក្តិ ៤០៨០

II.រាជរដ្ឋាភិបាល

១.អនុក្រឹត្យ

០៩-៦-២០០៩ -អនុក្រឹត្យលេខ ៨៤ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា ៤០៨២

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៧៧៤ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៤១០៦

២.សារាចរណែនាំ

១៥-៦-២០០៩ -សារាចរណែនាំលេខ ០៨ សរណន ស្តីពីការប្រារព្ធទិវាអតីតយុទ្ធជនកម្ពុជាលើកទី II ៤១៣១

III.ការងារបណ្តាក្រសួង

១.ទីស្តីការគណៈរដ្ឋមន្ត្រី

១៥-៦-២០០៩ -សេចក្តីសម្រេចលេខ ៥៩ សសរ ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសដើម្បីជំរុញ និងលើកកំពស់ប្រតិបត្តិការរបស់ក្រុមហ៊ុនអាកាសចរណ៍ Cambodia Angkor Air ៤១៣៣

២. ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

០៩-៦-២០០៩ -ប្រកាសលេខ ៣៦៤ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន អាយបើរ៉ាស៊ា ខូ អិលធីឌី បង្កើតរោងចក្រ "ផលិតសម្លៀកបំពាក់ (ចាក់)" ៤១៣៥

៣.ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១០-១០-២០០៨ -លិខិតបញ្ជាក់លេខ ៥៤៨២ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អិ ជូ អ៊ីមផត អិចផត ខូ អិលធីឌី ៤១៤០

ព្រះរាជក្រម

នស/រកម/០៦០៩/០០៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងទេសចរណ៍

ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីទេសចរណ៍ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី ២ នីតិកាលទី ៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ នាសម័យប្រជុំវិសាមញ្ញ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ ៖

UME DU CAMBODGE

ច្បាប់

ស្តីពី

ទេសចរណ៍

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ច្បាប់នេះមានគោលដៅកំណត់វិធាន និងយន្តការសម្រាប់គ្រប់គ្រងនិងអភិវឌ្ឍវិស័យទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២.-

ច្បាប់នេះមានគោលបំណង ដូចតទៅ :

-គ្រប់គ្រង និងអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយប្រសិទ្ធភាព គុណភាព និងនិរន្តរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ

-រួមចំណែកការពារ និងថែរក្សាធនធានធម្មជាតិ វប្បធម៌ និងទំនៀមទម្លាប់ដែលជាមូលដ្ឋានបម្រើឱ្យវិស័យទេសចរណ៍

-ធានា និងលើកកម្ពស់គុណភាពសេវាកម្មទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការបង្កើតប្រព័ន្ធធានាគុណភាព ដោយផ្តល់សន្តិសុខ សុវត្ថិភាព ផាសុកភាព និងបង្កើនការពេញចិត្តដល់ទេសចរ

-ទាញយកផលប្រយោជន៍ក្នុងវិស័យទេសចរណ៍ឱ្យបានជាអតិបរមា ធានាការបែងចែកប្រកបដោយសមធម៌ និងទប់ស្កាត់ផលប៉ះពាល់អវិជ្ជមាននៃវិស័យទេសចរណ៍

-លើកកម្ពស់កិច្ចសហប្រតិបត្តិការទូលំទូលាយ រកទីផ្សារ និងជំរុញការផ្សព្វផ្សាយទេសចរណ៍កម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាព ដោយមានការចូលរួមពីផ្នែកសាធារណៈ និងផ្នែកឯកជន

-អភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍

-រួមចំណែកកសាងមិត្តភាព និងការយោគយល់ជាអន្តរជាតិ តាមរយៈឧស្សាហកម្មទេសចរណ៍ ។

មាត្រា ៣.-

ច្បាប់នេះមានវិសាលភាពគ្រប់គ្រងនិងគ្របដណ្តប់លើរាល់សកម្មភាពទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៤.-

វាក្យស័ព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ ត្រូវកំណត់នៅក្នុងឧបសម្ព័ន្ធ ។

ជំពូកទី ២
គោលនយោបាយ និងផែនការអភិវឌ្ឍទេសចរណ៍

មាត្រា ៥.-

ក្រសួងទេសចរណ៍ ត្រូវរៀបចំគោលនយោបាយ និងផែនការអភិវឌ្ឍទេសចរណ៍សម្រាប់ព្រះរាជាណាចក្រកម្ពុជា ដោយមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ សមាគមឧស្សាហកម្មទេសចរណ៍ និង ផ្នែកឯកជនដែលមានការពាក់ព័ន្ធ ។

ផែនការអភិវឌ្ឍទេសចរណ៍ រួមមាន ផែនការអភិវឌ្ឍទេសចរណ៍ថ្នាក់ជាតិ ផែនការអភិវឌ្ឍទេសចរណ៍ថ្នាក់តំបន់ និងផែនការអភិវឌ្ឍទេសចរណ៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។ រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំផែនការអភិវឌ្ឍទេសចរណ៍ សម្រាប់មូលដ្ឋានរបស់ខ្លួន ។

មាត្រា ៦.-

ផែនការអភិវឌ្ឍទេសចរណ៍ថ្នាក់ជាតិ ត្រូវ :

ក-កំណត់គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការជាតិសម្រាប់ការអភិវឌ្ឍ និងផ្សព្វផ្សាយអំពីវិស័យទេសចរណ៍កម្ពុជា ។

ខ-លើកឡើងរាល់វិធានការ ដើម្បីកាត់បន្ថយភាពក្រីក្រ និងធានាឱ្យបាននូវនិរន្តរភាពនៃការអភិវឌ្ឍវិស័យទេសចរណ៍ថ្នាក់ជាតិ ។

គ-ធ្វើសមាហរណកម្មជាមួយផែនការទេសចរណ៍អាស៊ាននិងផែនការទេសចរណ៍អន្តរជាតិនានា ។

មាត្រា ៧.-

ផែនការអភិវឌ្ឍទេសចរណ៍ថ្នាក់តំបន់ និងផែនការអភិវឌ្ឍទេសចរណ៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវ :

ក-កំណត់យុទ្ធសាស្ត្រអភិវឌ្ឍវិស័យទេសចរណ៍តាមតំបន់ និងនៅថ្នាក់រដ្ឋបាលក្រោមជាតិ ។

ខ-លើកឡើងនូវវិធានការនានាដើម្បីកាត់បន្ថយភាពក្រីក្រ និងដើម្បីធានាឱ្យបាននូវនិរន្តរភាពនៃការអភិវឌ្ឍ និងការគ្រប់គ្រងវិស័យទេសចរណ៍ នៅតាមតំបន់ និងនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិ ។

ផែនការអភិវឌ្ឍទេសចរណ៍ថ្នាក់តំបន់ ត្រូវរៀបចំឡើងឱ្យស្របទៅតាមផែនការអភិវឌ្ឍទេសចរណ៍ថ្នាក់ជាតិ ។ ផែនការអភិវឌ្ឍទេសចរណ៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំឡើងឱ្យស្របទៅតាមផែនការអភិវឌ្ឍទេសចរណ៍ថ្នាក់តំបន់ ។

មាត្រា ៨.-

ផែនការអភិវឌ្ឍទេសចរណ៍ថ្នាក់ជាតិ និងថ្នាក់តំបន់ ត្រូវដាក់ជូនរាជរដ្ឋាភិបាល ដើម្បីអនុម័ត និងបញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ដើម្បីឱ្យក្លាយទៅជាគោលនយោបាយ និងយុទ្ធសាស្ត្រទូទៅរបស់រាជរដ្ឋាភិបាលសម្រាប់វិស័យទេសចរណ៍នៅព្រះរាជាណាចក្រកម្ពុជា ។

ផែនការអភិវឌ្ឍទេសចរណ៍ត្រូវពិនិត្យ និងកែប្រែឡើងវិញតាមភាពចាំបាច់ យ៉ាងហោចណាស់មួយដងរៀងរាល់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ។

ជំពូកទី ៣

សមត្ថកិច្ចគ្រប់គ្រង

មាត្រា ៩.-

ក្រសួងទេសចរណ៍មានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងការងារវិស័យទេសចរណ៍និងបំពេញភារកិច្ចផ្សេងៗទៀតឱ្យមានប្រសិទ្ធភាពស្របទៅតាមការអនុវត្តជាលក្ខណៈជាតិ និងអន្តរជាតិ ។

ក្រសួងទេសចរណ៍ត្រូវដឹកនាំ និងត្រួតពិនិត្យការអនុវត្តផែនការអភិវឌ្ឍទេសចរណ៍ ។ ដោយវិស័យទេសចរណ៍ប៉ះពាល់ទៅលើ និងទទួលរងការប៉ះពាល់ពីការងារ និងសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន និងអាជ្ញាធរជាច្រើនទៀត ការបែងចែកតួនាទីរបស់ក្រសួងទេសចរណ៍ជាមួយ ត្រូវធ្វើឡើងស្របទៅតាមគោលការណ៍ដែលបានគូសបញ្ជាក់នៅក្នុងមាត្រានានាដូចខាងក្រោម ។

មាត្រា ១០.-

ក្រសួងទេសចរណ៍ ត្រូវទទួលខុសត្រូវជាចម្បងក្នុងការចេញបទប្បញ្ញត្តិសំខាន់ៗផ្នែកឧស្សាហកម្មទេសចរណ៍ ដើម្បីជំរុញការអនុវត្តផែនការអភិវឌ្ឍទេសចរណ៍ឱ្យមានប្រសិទ្ធភាព ។ ផ្នែកសំខាន់ៗទាំងនោះ រួមមាន :

- ការផ្សព្វផ្សាយវិស័យទេសចរណ៍ក្នុង និងក្រៅព្រះរាជាណាចក្រកម្ពុជា
- ការធានាគុណភាពនៅក្នុងវិស័យទេសចរណ៍
- ស្តង់ដារនានានៃវិស័យទេសចរណ៍
- អាជ្ញាបណ្ណទេសចរណ៍
- សកម្មភាពអាជីវកម្មទេសចរណ៍
- ការណែនាំភាគីពាក់ព័ន្ធក្នុងវិស័យទេសចរណ៍
- ការគ្រប់គ្រង និងការត្រួតពិនិត្យព័ត៌មានទេសចរណ៍
- សហប្រតិបត្តិការអន្តរជាតិក្នុងវិស័យទេសចរណ៍ ជាមួយប្រទេសជិតខាង និងពិភពលោក ។

ក្រសួងទេសចរណ៍ត្រូវពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន និង អាជ្ញាធរពាក់ព័ន្ធ ក្នុងករណីដែលក្រសួង ស្ថាប័ន ឬ អាជ្ញាធរណាមួយនោះ មានចំណាប់អារម្មណ៍ប្រឹក្សាយោបល់លើផ្នែកណាមួយនៃឧស្សាហកម្មទេសចរណ៍ ។

មាត្រា ១១.-

ក្រសួងទេសចរណ៍ត្រូវមានការទទួលខុសត្រូវរួមគ្នាជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធដទៃទៀត ក្នុងការចេញបទប្បញ្ញត្តិសំខាន់ៗដែលប៉ះពាល់ទៅលើ ឬ ទទួលរងការប៉ះពាល់ដោយឧស្សាហកម្មទេសចរណ៍ ។ ផ្នែកសំខាន់ៗទាំងនោះ រួមមាន :

- សមាគមឧស្សាហកម្មទេសចរណ៍
- ការការពារបរិស្ថាន
- ការការពារ និងការបង្ហាញពីមរតកធម្មជាតិ
- ការការពារ និងការបង្ហាញពីមរតកវប្បធម៌
- ការវិនិយោគវិស័យទេសចរណ៍ និងការលើកទឹកចិត្ត
- ការគ្រប់គ្រង និងឯកជនភាវូបនីយកម្មនៃសហគ្រាសទេសចរណ៍របស់រដ្ឋ

-ការគ្រប់គ្រងដីធ្លីរបស់រដ្ឋដែលបានផ្តល់សម្រាប់គោលបំណងទេសចរណ៍

-ការទប់ស្កាត់ការធ្វើអាជីវកម្មផ្លូវភេទ

-ការអភិវឌ្ឍផលិតផលទេសចរណ៍

-អេកូទេសចរណ៍

-សហគមន៍ទេសចរណ៍មូលដ្ឋាន

-ការកាត់បន្ថយភាពក្រីក្រ

-អនាម័យ និងសុវត្ថិភាពចំណីអាហារ

-សន្តិសុខ និងសុវត្ថិភាពទេសចរ

-នគរបាលទេសចរណ៍ ។

ក្រសួងទេសចរណ៍ ក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធ ត្រូវសហការគ្នា ដើម្បីធានាថាផ្នែកនានានៅក្នុងឧស្សាហកម្មទេសចរណ៍ត្រូវបានចាត់ចែង និងគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងឆ្លើយតបទៅតាមផែនការអភិវឌ្ឍទេសចរណ៍ ។

មាត្រា ១២.-

ក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធដែលការងាររបស់ខ្លួនប៉ះពាល់ទៅដល់ឧស្សាហកម្មទេសចរណ៍ និងផែនការអភិវឌ្ឍទេសចរណ៍ ត្រូវពិគ្រោះយោបល់ផ្នែកជំនាញទេសចរណ៍ពីក្រសួងទេសចរណ៍ ។ ផ្នែកដែលប៉ះពាល់ទៅលើ ឬ ទទួលរងការប៉ះពាល់ដោយឧស្សាហកម្មទេសចរណ៍ អាចរួមមាន :

-ផែនការប្រើប្រាស់ដីធ្លី

-ផែនការរូបវន្ត និងផែនការអភិវឌ្ឍ

-ហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈ

-ការផ្តល់ឱ្យភាពជាម្ចាស់កម្មសិទ្ធិ ភតិសន្យា ឬ សម្បទានសម្រាប់គោលបំណងទេសចរណ៍

-ការកសាងគោលនយោបាយពន្ធដារលើអាជីវកម្មទេសចរណ៍

-ទិដ្ឋាការ

-គោលនយោបាយអាកាសចរណ៍ ។

ដើម្បីធានាការអនុវត្តឱ្យមានប្រសិទ្ធភាព រាល់គម្រោងសាងសង់សំណង់បម្រើឱ្យសកម្មភាពទេសចរណ៍ ត្រូវធ្វើឡើងឱ្យស្របតាមផែនការអភិវឌ្ឍទេសចរណ៍ និង ត្រូវមានការផ្តល់យោបល់ផ្នែកជំនាញទេសចរណ៍ពីក្រសួងទេសចរណ៍ ។

ក្រសួងទេសចរណ៍ ផ្តល់ដំបូន្មានបច្ចេកទេស ទៅដល់គណៈកម្មការគ្រប់គ្រង និង អភិវឌ្ឍទេសចរណ៍រាជធានី ខេត្ត និងថ្នាក់មូលដ្ឋាន ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍កម្ពុជា សមាគមឧស្សាហកម្មទេសចរណ៍ និងប្រតិបត្តិករទេសចរណ៍ ។

មាត្រា ១៣.-

ក្នុងករណីចាំបាច់ ក្រសួងទេសចរណ៍ព្រមទាំងក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធ អាចចេញបទប្បញ្ញត្តិផ្សេងៗរួមគ្នា ដើម្បីចាត់ចែង និងគ្រប់គ្រងការងារដូចមានចែងក្នុងមាត្រា ១១ និងមាត្រា ១២ នៃច្បាប់នេះឱ្យមានប្រសិទ្ធភាព ។

ជំពូកទី ៤
ស្ថាប័ន និងហិរញ្ញប្បទាន

មាត្រា ១៤.-

ក្រសួងទេសចរណ៍ត្រូវពង្រឹង និងពង្រីករចនាសម្ព័ន្ធចាត់តាំងរបស់ខ្លួនឱ្យឆ្លើយតបតាមផែនការអភិវឌ្ឍទេសចរណ៍ ។

មាត្រា ១៥.-

ក្រសួងទេសចរណ៍ត្រូវរៀបចំបង្កើតវិទ្យាស្ថានជាតិទេសចរណ៍ ។ វិទ្យាស្ថានជាតិទេសចរណ៍ជាមណ្ឌលសិក្សា និងស្រាវជ្រាវអំពីវិស័យទេសចរណ៍ក្នុងគោលបំណងបង្កើតគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍទេសចរណ៍ប្រកបដោយប្រសិទ្ធភាព គុណភាព និងនិរន្តរភាព ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃវិទ្យាស្ថានជាតិទេសចរណ៍នេះត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ១៦.-

ក្រសួងទេសចរណ៍ត្រូវរៀបចំបង្កើតសាលាវិជ្ជាជីវៈទេសចរណ៍ ។ សាលាវិជ្ជាជីវៈទេសចរណ៍នេះមានបេសកកម្មអប់រំបណ្តុះបណ្តាល អ្នកឯកទេសវិជ្ជាជីវៈផ្នែកទេសចរណ៍

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

សណ្ឋាគារ និងបដិសណ្ឋារកិច្ចសំដៅបម្រើឱ្យឧស្សាហកម្មទេសចរណ៍ ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃសាលាវិជ្ជាជីវៈទេសចរណ៍នេះត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ១៧.-

ក្រសួងទេសចរណ៍ត្រូវរៀបចំបង្កើតសកលវិទ្យាល័យទេសចរណ៍ និងបដិសណ្ឋារកិច្ច ។ សកលវិទ្យាល័យទេសចរណ៍ និងបដិសណ្ឋារកិច្ចជាគ្រឹះស្ថានឧត្តមសិក្សាដែលមានការអប់រំ និងបណ្តុះបណ្តាលធនធានមនុស្សលើគ្រប់ជំនាញនៃវិស័យទេសចរណ៍ និងបដិសណ្ឋារកិច្ច ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃសកលវិទ្យាល័យទេសចរណ៍ និងបដិសណ្ឋារកិច្ចត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ១៨.-

ក្រសួងទេសចរណ៍សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធត្រូវទទួលស្គាល់តួនាទីដ៏មានតម្លៃរបស់ផ្នែកឯកជនក្នុងការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជំនាញទេសចរណ៍ សណ្ឋាគារ និងបដិសណ្ឋារកិច្ច ដូចបានកំណត់ក្នុងបទប្បញ្ញត្តិនានាដែលមានចែងក្នុងជំពូកទី ៥ នៃច្បាប់នេះ ។

មាត្រា ១៩.-

ក្រសួងទេសចរណ៍ជួយសម្រួលការងារទាំងឡាយក្នុងការបង្កើតធម្មនុញ្ញ និង/ ឬ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងត្រួតពិនិត្យសកម្មភាពរបស់សមាគមឧស្សាហកម្មទេសចរណ៍ ។

សមាគមឧស្សាហកម្មទេសចរណ៍ត្រូវមានធម្មនុញ្ញ និង/ ឬ លក្ខន្តិកៈ ឬ បទបញ្ជាផ្ទៃក្នុងឱ្យស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិផ្សេងៗជាធរមាន ។

មាត្រា ២០.-

ក្រសួងទេសចរណ៍ត្រូវរៀបចំបង្កើតក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និង ផ្សព្វផ្សាយទេសចរណ៍កម្ពុជាមានអក្សរកាត់ថា "ក.ផ.ផ." ក្នុងលក្ខណៈជាដៃគូជាមួយផ្នែកឯកជននិងផ្នែកសាធារណៈ ។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជាត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ២១.-

ហិរញ្ញប្បទានទ្រទ្រង់ការអភិវឌ្ឍ និងគ្រប់គ្រងវិស័យទេសចរណ៍បានមកពី :

-ថវិកាជាតិប្រចាំឆ្នាំរបស់ក្រសួងទេសចរណ៍

-ហិរញ្ញប្បទានសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍនានា

-ការបរិច្ចាគរបស់សប្បុរសជន អតិថិជន និងសមាគមឧស្សាហកម្មទេសចរណ៍

-ការបរិច្ចាគរបស់ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា

-ការបរិច្ចាគរបស់ប្រតិបត្តិករទេសចរណ៍

-ប្រភពហិរញ្ញប្បទាន ឬ ចំណូលស្របច្បាប់ផ្សេងៗទៀត ។

ការគ្រប់គ្រង និងការប្រើប្រាស់ថវិកាសម្រាប់អភិវឌ្ឍវិស័យទេសចរណ៍ ត្រូវកំណត់ដោយប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ជំពូកទី ៥

គុណភាព ស្តង់ដារ និងអាជ្ញាបណ្ណទេសចរណ៍

មាត្រា ២២.-

ក្រសួងទេសចរណ៍ត្រូវត្រួតពិនិត្យលើការចាត់ចែងរាល់អាជីវកម្ម និងសកម្មភាពទេសចរណ៍តាមរយៈការផ្តល់អាជ្ញាបណ្ណ ការបង្កើតប្រព័ន្ធចំណាត់ថ្នាក់ កំណត់ស្តង់ដារ អប្បបរមា និងប្រព័ន្ធអនុវត្តនានាដើម្បីបង្កើត កែលំអ និងរក្សាគុណភាពសេវាកម្មទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២៣.-

ក្រសួងទេសចរណ៍ត្រូវកំណត់ស្តង់ដារ និងការតម្រូវលើបញ្ហាបច្ចេកទេសសេវាកម្មទេសចរណ៍ឱ្យស្របទៅនឹងលក្ខខណ្ឌអនុវត្តដ៏ប្រសើរបំផុត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ អាជីវកម្មទេសចរណ៍ទាំងអស់ត្រូវអនុវត្តទៅតាមស្តង់ដារ និងការតម្រូវ ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

មាត្រា ២៤.-

ក្រសួងទេសចរណ៍ត្រូវរៀបចំបង្កើតប្រព័ន្ធចំណាត់ថ្នាក់សណ្ឋាគារនិង សេវាកម្មស្នាក់នៅទេសចរណ៍ និងសេវាកម្មទេសចរណ៍ផ្សេងៗទៀតស្របទៅតាមស្តង់ដារអន្តរជាតិ និងលក្ខខណ្ឌអនុវត្តដ៏ប្រសើរបំផុតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ប្រព័ន្ធចំណាត់ថ្នាក់សណ្ឋាគារនិងសេវាកម្មស្នាក់នៅទេសចរណ៍ត្រូវកំណត់ដោយអនុក្រឹត្យ ។ ប្រព័ន្ធចំណាត់ថ្នាក់សម្រាប់សេវាកម្មទេសចរណ៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ។

មាត្រា ២៥.-

ក្រោយពេលប្រព័ន្ធចំណាត់ថ្នាក់ត្រូវបង្កើតឡើងសម្រាប់សកម្មភាពអាជីវកម្មទេសចរណ៍ណាមួយនោះ អាជ្ញាបណ្ណទេសចរណ៍ដែលចេញក្រោមច្បាប់នេះ ត្រូវបញ្ជាក់ពីកម្រិតថ្នាក់របស់អាជីវកម្មនោះ ។

មាត្រា ២៦.-

ក្រសួងទេសចរណ៍ត្រូវណែនាំវិធានការ សម្រាប់បង្កើនការធានាគុណភាពសេវាកម្មទេសចរណ៍ផ្សេងទៀត ដូចជាស្លាកសញ្ញាពិសេស ស្លាកសញ្ញាបញ្ជាក់គុណភាព ការទទួលស្គាល់គុណភាព រង្វាន់ និងការលើកទឹកចិត្ត ។

ក្រសួងទេសចរណ៍ ត្រូវពិគ្រោះយោបល់ជាមួយឧស្សាហកម្មទេសចរណ៍ និងក្រុមអ្នកពាក់ព័ន្ធផ្សេងៗ ក្នុងការរៀបចំគំនូសបំព្រួញ ការអភិវឌ្ឍ និងការអនុវត្តវិធានការទាំងនោះ ។

លក្ខណៈពិសេសនៃស្លាកសញ្ញាពិសេស ស្លាកសញ្ញាបញ្ជាក់គុណភាព ការទទួលស្គាល់គុណភាព រង្វាន់ និងការលើកទឹកចិត្តត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ។

មាត្រា ២៧.-

ដើម្បីលើកទឹកចិត្តចំពោះការធានាគុណភាពផលិតផល និងសេវាកម្មក្នុងឧស្សាហកម្មទេសចរណ៍ ក្រសួងទេសចរណ៍ត្រូវបង្កើតស្លាកសញ្ញាបរិស្ថានពិសេស មួយហៅថា "**អេកូឡាប៊ែល**" ទុកជូនជារង្វាន់លើកទឹកចិត្តដល់ប្រតិបត្តិករទេសចរណ៍ណាដែលបានអនុវត្តត្រឹមត្រូវតាមស្តង់ដារបរិស្ថានរបស់ក្រសួងបរិស្ថាន ។ មានតែប្រតិបត្តិករទេសចរណ៍ ដែលជាអ្នក

ROYAUME DU CAMBODGE * PALAIS ROYAL
ព្រះបរមរាជវាំង

បានទទួលរង្វាន់សញ្ញាបរិស្ថានពិសេសទេ ទើបអាចប្រើប្រាស់ស្លាកនេះ សម្រាប់បិទនៅលើផលិតផល និងសេវាកម្មបម្រើឱ្យសាធារណជន និងអតិថិជនរបស់គេបាន ។

មាត្រា ២៨.-

ប្រតិបត្តិករទេសចរណ៍ដែលជាម្ចាស់ស្លាកសញ្ញាបរិស្ថានពិសេស ដែលផ្តល់ដោយក្រសួងទេសចរណ៍ អាចទទួលបានអត្ថប្រយោជន៍ និងការលើកទឹកចិត្តជាអាទិភាពពីរាជរដ្ឋាភិបាលមុនប្រតិបត្តិករទេសចរណ៍ដទៃទៀត ។ ក្នុងចំណោមអត្ថប្រយោជន៍ និងការលើកទឹកចិត្តទាំងនោះមាន :

-សិទ្ធិក្នុងការធ្វើអាជីវកម្មក្នុងតំបន់ពិសេសមួយចំនួន
-ការកាត់បន្ថយថ្លៃចេញអាជ្ញាបណ្ណទេសចរណ៍
-ការផ្សព្វផ្សាយនៅក្នុងប្រព័ន្ធគេហទំព័រអ្នកទទួលរង្វាន់ពិសេស
-ការផ្សព្វផ្សាយនៅក្នុងសៀវភៅអ្នកទទួលរង្វាន់ពិសេស
-ការទទួលអាទិភាពនៅក្នុងយុទ្ធនាការផ្សព្វផ្សាយ ។

មាត្រា ២៩.-

ប្រតិបត្តិករទេសចរណ៍ដែលផ្តល់សេវាកម្មល្អ អាចទទួលរង្វាន់ពិសេសពីក្រសួងទេស-ចរណ៍ ឬ រាជរដ្ឋាភិបាល ឬ ពីព្រះមហាក្សត្រ ។ នីតិវិធី និងលក្ខណវិនិច្ឆ័យលម្អិតសម្រាប់រង្វាន់ពិសេសនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

មានតែប្រតិបត្តិករទេសចរណ៍ដែលបានទទួលនូវរង្វាន់ពិសេសនេះទេ ទើបអាចប្រើប្រាស់រង្វាន់ពិសេសនេះបាន នៅក្នុងការទាក់ទងជាមួយសាធារណជន និង អតិថិជនរបស់គេ ។

មាត្រា ៣០.-

សកម្មភាពអាជីវកម្មទេសចរណ៍ ដូចចែងក្នុងជំពូកទី ៣ នៃច្បាប់នេះ ត្រូវបានចាត់ទៅតាមប្រភេទ និងការទទួលខុសត្រូវរបស់ក្រសួងទេសចរណ៍ ដូចតទៅ :

ក- សកម្មភាពអាជីវកម្មទេសចរណ៍នៅក្នុងផ្នែកដែលមានការទទួលខុសត្រូវជាផ្ទាល់ ដូចមានចែងក្នុងមាត្រា ១០ នៃច្បាប់នេះ មានជាអាទិ៍ដូចតទៅ :

ROYAUME DU CAMBODGE - LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

-មគ្គុទ្ទេសក៍ទេសចរណ៍

-ការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍

-ព័ត៌មាន និងការផ្សព្វផ្សាយទេសចរណ៍

-សេវាកម្មស្នាក់នៅទេសចរណ៍

-រមណីយដ្ឋានទេសចរណ៍

-គោលដៅទាក់ទាញទេសចរណ៍

-សេវាកម្មដឹកជញ្ជូនទេសចរណ៍

-អាហារដ្ឋាន និងភោជនីយដ្ឋានទេសចរណ៍

-សាលាវិជ្ជាជីវៈទេសចរណ៍

-មណ្ឌលកម្សាន្តទេសចរណ៍

-មណ្ឌលកម្សាន្តទេសចរណ៍សម្រាប់មនុស្សពេញវ័យ

-សកម្មភាពកីឡាទេសចរណ៍

-ព្រឹត្តការណ៍ និងពិព័រណ៍ទេសចរណ៍ ។

ខ- សកម្មភាពអាជីវកម្មទេសចរណ៍នៅក្នុងផ្នែកដែលមានការទទួលខុសត្រូវរួមគ្នា ដូចមានចែងក្នុងមាត្រា ១១ នៃច្បាប់នេះ មានជាអាទិ៍ដូចតទៅ :

-អាហារដ្ឋាន និងភោជនីយដ្ឋានទទួលបម្រើភ្ញៀវក្នុងស្រុក

-សេវាកម្មដឹកជញ្ជូនអ្នកធ្វើដំណើរក្នុងស្រុក

-តំបន់ការពារធម្មជាតិ

-តំបន់សត្វផ្សោតទន្លេមេគង្គ

-សកម្មភាពអេកូទេសចរណ៍

-សកម្មភាពសហគមន៍ទេសចរណ៍មូលដ្ឋាន

-សេវាកម្មលក់ដូរវត្ថុអនុស្សាវរីយ៍

-គ្រឹះស្ថានសិក្សាទេសចរណ៍ សណ្ឋាគារ និងបដិសណ្ឋារកិច្ច ។

គ- សកម្មភាពអាជីវកម្មទេសចរណ៍នៅក្នុងផ្នែកដែលមានការទទួលខុសត្រូវដោយ ក្រសួងពាក់ព័ន្ធផ្ទាល់ ដូចមានចែងក្នុងមាត្រា ១២ នៃច្បាប់នេះ មានជាអាទិ៍ ដូចតទៅ :

-ការដឹកជញ្ជូនអ្នកធ្វើដំណើរតាមផ្លូវអាកាស

-ទីតាំងបេតិកភណ្ឌវប្បធម៌របស់ជាតិ

-ទីតាំងបេតិកភណ្ឌធម្មជាតិរបស់ជាតិ

-សេវាកម្មរៀបចំសន្និសីទ ពិព័រណ៍ ព្រឹត្តិការណ៍ និងបុណ្យជាតិ អន្តរជាតិ ។

ក្រសួងទេសចរណ៍អាចធ្វើការកែសម្រួលប្រភេទនៃសកម្មភាពអាជីវកម្មទេសចរណ៍ និងការទទួលខុសត្រូវរបស់ខ្លួនបានស្របតាមការចាំបាច់ ឬ ការតម្រូវដែលមានកំណត់នៅក្នុងផែនការអភិវឌ្ឍទេសចរណ៍ ។

មាត្រា ៣១.-

ដើម្បីអនុវត្តឱ្យស្របតាមមាត្រា ១០ នៃជំពូកទី ៣ និងបទប្បញ្ញត្តិដែលមានចែងក្នុងជំពូកទី ៩ នៃច្បាប់នេះ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ត្រូវចេញប្រកាស ដើម្បីគ្រប់គ្រងការផ្តល់អាជ្ញាបណ្ណលើសកម្មភាពអាជីវកម្មទេសចរណ៍ តាមផ្នែកដែលក្រសួងទេសចរណ៍ទទួលខុសត្រូវជាចម្បង ។

ក្រសួងទេសចរណ៍ព្រមទាំងក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធ ត្រូវសហការចេញប្រកាសរួម ដើម្បីគ្រប់គ្រងផ្នែកដែលមានការទទួលខុសត្រូវរួមឱ្យស្របតាមមាត្រា ១១ នៃជំពូកទី ៣ និងបទប្បញ្ញត្តិនៃជំពូកទី ៩ នៃច្បាប់នេះ ។

មាត្រា ៣២.-

រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ត្រូវចេញប្រកាសអំពីប្រភេទនៃសកម្មភាពអាជីវកម្មទេសចរណ៍ដែលតម្រូវឱ្យមានអាជ្ញាបណ្ណពីក្រសួងទេសចរណ៍ ឬ ពីរដ្ឋបាលថ្នាក់ក្រោមជាតិ ។

គ្មានបុគ្គលណាម្នាក់អាចប្រកបអាជីវកម្មទេសចរណ៍បានទេ ប្រសិនបើបុគ្គលនោះមិនបានទទួលការផ្តល់អាជ្ញាបណ្ណទេសចរណ៍ពីក្រសួងទេសចរណ៍ ឬ ពីរដ្ឋបាលថ្នាក់ក្រោមជាតិ ។ ក្នុងករណីដែលអាជីវកម្មច្រើនប្រភេទត្រូវបានប្រតិបត្តិ ដោយបុគ្គលតែម្នាក់ ចេញពីទីតាំងតែមួយ ប្រភេទអាជីវកម្មនីមួយៗត្រូវតែមានអាជ្ញាបណ្ណផ្សេងៗគ្នា ប្រៀបដូចជាអាជីវកម្មផ្សេងគ្នាដែលប្រតិបត្តិចេញពីទីតាំងផ្សេងគ្នាយ៉ាងដូច្នោះដែរ ។

ក្នុងករណីដែលបុគ្គលម្នាក់មានអាជីវកម្មទេសចរណ៍មួយប្រភេទ ហើយមានសាខាច្រើនកន្លែង សាខានីមួយៗនោះត្រូវតែមានអាជ្ញាបណ្ណទេសចរណ៍ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

មាត្រា ៣៣.–

អាជ្ញាបណ្ណទេសចរណ៍ ដែលចេញដោយក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិ មិនធ្វើឱ្យប្រតិបត្តិករទេសចរណ៍រួចផុតពីកាតព្វកិច្ចក្នុងការចុះបញ្ជីពាណិជ្ជកម្ម ឬ ទទួលការអនុញ្ញាតពីក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធដែលតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិជាធរមានឡើយ ។ ក្រសួងទេសចរណ៍សហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធដើម្បីបង្កើនប្រសិទ្ធភាពនៃដំណើរការផ្តល់អាជ្ញាបណ្ណទេសចរណ៍ ។

មាត្រា ៣៤.–

ក្រសួងទេសចរណ៍ ដោយមានការពិគ្រោះយោបល់ជាមួយផ្នែកឯកជន ក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធត្រូវកំណត់ស្តង់ដារអប្បបរមា និងលក្ខណវិនិច្ឆ័យដទៃទៀតសម្រាប់ប្រភេទនីមួយៗនៃអាជ្ញាបណ្ណទេសចរណ៍ ដែលរៀបចំឡើងដើម្បីបង្កើត កែលម្អ និងរក្សាគុណភាពសេវាកម្មទេសចរណ៍ ។

លក្ខណវិនិច្ឆ័យទាំងនោះត្រូវឱ្យស្របទៅតាមប្រភេទនីមួយៗនៃអាជ្ញាបណ្ណទេសចរណ៍ និងត្រូវមានទំនាក់ទំនងជាមួយកម្មវត្ថុមួយចំនួន ឬ ទាំងអស់ក្នុងចំណោមកម្មវត្ថុទាំងឡាយដូចខាងក្រោម :

ក-សញ្ជាតិ គុណវុឌ្ឍិ បទពិសោធន៍ ចំណេះដឹង និងអត្តចរិតរបស់ប្រតិបត្តិករ និងបុគ្គលិកសំខាន់ៗ ។

ខ-ទីតាំង អគារ បរិក្ខារ ការចុះបញ្ជី និងសមត្ថភាពហិរញ្ញវត្ថុរបស់ប្រតិបត្តិករ ។

លក្ខណវិនិច្ឆ័យសម្រាប់ប្រភេទនៃអាជ្ញាបណ្ណទេសចរណ៍នីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ។

មាត្រា ៣៥.–

លក្ខណវិនិច្ឆ័យសម្រាប់ការចេញអាជ្ញាបណ្ណទេសចរណ៍ឱ្យមគ្គុទ្ទេសក៍ទេសចរណ៍ត្រូវមានជាអាទិ៍ដូចខាងក្រោម :

ក-ត្រូវតែជាបុគ្គលដែលមានសញ្ជាតិខ្មែរ និងមានអាយុចាប់ពី ១៨ ឆ្នាំឡើង

ខ-មានវិញ្ញាបនបត្រជំនាញមគ្គុទ្ទេសក៍ទេសចរណ៍ ដែលការបណ្តុះបណ្តាលត្រូវបានទទួលស្គាល់ដោយក្រសួងទេសចរណ៍ ។

លក្ខណវិនិច្ឆ័យផ្សេងទៀតដើម្បីផ្តល់អាជ្ញាបណ្ណឱ្យមគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៣៦.–

ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ ឬ ពាក្យស្នើសុំបន្តអាជ្ញាបណ្ណទេសចរណ៍ ត្រូវធ្វើឡើងដោយប្រតិបត្តិករទេសចរណ៍ជាសំណុំបែបបទ រួមទាំងឯកសារសម្អាង និង ព័ត៌មានផ្សេងៗទៀត ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ។

ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ត្រូវតែភ្ជាប់មកជាមួយនូវកម្រៃអាជ្ញាបណ្ណ ដែលត្រូវបានកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

មាត្រា ៣៧.–

ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍នឹងយកមកធ្វើការវិនិច្ឆ័យ នៅពេលដែលក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិពិនិត្យឃើញថា សាមីជនបានបំពេញត្រឹមត្រូវតាមទម្រង់បែបបទនៃគំរូពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ ។

មាត្រា ៣៨.–

ក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវពិនិត្យ និងវាយតម្លៃលើពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ដោយផ្អែកលើព័ត៌មានដែលបានទទួល ឬ សាកសួរបន្ថែមទៀតតាមការចាំបាច់ ។

ក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវជូនដំណឹងទៅអ្នកស្នើសុំអាជ្ញាបណ្ណទេសចរណ៍អំពីសេចក្តីសម្រេចឯកភាពផ្តល់ឱ្យ ឬ មិនឯកភាពផ្តល់ឱ្យក្នុងរយៈពេល ២៨ (ម្ភៃប្រាំបី) ថ្ងៃ ចាប់ពីថ្ងៃបានទទួលពាក្យស្នើសុំពេញលេញ ។ ក្នុងករណីមិនឯកភាពផ្តល់ឱ្យអាជ្ញាបណ្ណទេសចរណ៍ ក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបញ្ជាក់ពីមូលហេតុច្បាស់លាស់ជូនទៅសាមីជន ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

មន្ត្រីក្រសួងទេសចរណ៍ ឬ មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិដែលទទួលខុសត្រូវក្នុងការពិនិត្យ និងវាយតម្លៃពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ ដែលពាក់ព័ន្ធនឹងផលប្រយោជន៍ផ្ទាល់ខ្លួន ពុំអាចឱ្យចូលរួមក្នុងដំណើរការអនុម័តលើពាក្យស្នើសុំនេះទេ ។

មាត្រា ៣៩.-

អាជ្ញាបណ្ណដែលបានចេញក្រោមច្បាប់នេះ ត្រូវមានលក្ខខណ្ឌដែលអ្នកទទួល ត្រូវអនុវត្តតាម ។ លក្ខខណ្ឌទាំងនោះ មានដូចតទៅ :

ក-អនុវត្តតាមផែនការ បទដ្ឋានស្តីពីសំណង់អគារ សុវត្ថិភាពអគ្គិភ័យ សុខភាពម្ហូបអាហារ អនាម័យ កម្លាំងពលកម្ម ពន្ធ ច្បាប់ និង បទប្បញ្ញត្តិដទៃទៀត ដែលទាក់ទងទៅនឹងសកម្មភាព ទីបរិវេណ បរិក្ខារ និយោជិត និងប្រតិបត្តិការអាជីវកម្មទេសចរណ៍ ។

ខ-អនុវត្តតាមស្តង់ដារ និងការតម្រូវដែលបានចេញដោយក្រសួងទេសចរណ៍ ដូចមានចែងក្នុងមាត្រា ២៣ នៃច្បាប់នេះ ។

គ-អនុវត្តតាមប្រព័ន្ធចំណាត់ថ្នាក់ ដែលបានចេញដោយក្រសួងទេសចរណ៍ ដូចមានចែងក្នុងមាត្រា ២៤ និងមាត្រា ២៥ នៃច្បាប់នេះ ។

ឃ-អនុវត្តតាមវិធានការធានាគុណភាព ដែលចេញដោយក្រសួងទេសចរណ៍ ដូចមានចែងក្នុងមាត្រា ២៨ នៃច្បាប់នេះ និងមិនប្រឌិតព័ត៌មានអំពីស្លាកសញ្ញាពិសេស ស្លាកសញ្ញាបញ្ជាក់គុណភាព ការទទួលស្គាល់គុណភាព រង្វាន់ ឬ ការលើកទឹកចិត្តដែលអាជីវកម្មនោះ មិនមានត្រឹមត្រូវនោះឡើយ ។

ង-ប្រសិនបើអាជីវកម្មទេសចរណ៍ត្រូវបានផ្តល់ឱ្យមានចំណាត់ថ្នាក់កម្រិតណាមួយដូចបានចែងនៅក្នុងមាត្រា ២៤ និងមាត្រា ២៥ នៃច្បាប់នេះ ចំណាត់ថ្នាក់នោះ ត្រូវតែដាក់តាំងនៅកន្លែងដែលងាយមើលឃើញក្នុងទីតាំងអាជីវកម្មរបស់ម្ចាស់អាជ្ញាបណ្ណ ហើយត្រូវតែបញ្ជាក់នូវគ្រប់ការធ្វើការងាររកទីផ្សារ ការផ្សាយពាណិជ្ជកម្ម និងការសរសេរឡើយផង ។

ច-អនុវត្តតាមក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈ ដែលចេញដោយក្រសួងទេសចរណ៍ ឬ ដោយសមាគមឧស្សាហកម្មទេសចរណ៍ ដែលមានការយល់ព្រមពីក្រសួងទេសចរណ៍ សម្រាប់អាជីវកម្មទេសចរណ៍ប្រភេទនោះ ។

ROYAUME DU CAMBODGE
REGISTRE PALAIS ROYAL

៤៧.

ឆ-ផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរដល់ក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងរយៈពេល ១៤ (ដប់បួន) ថ្ងៃ ក្រោយពីមានការផ្លាស់ប្តូរចំណុចពិស្តារណាមួយដែលទាក់ទងទៅនឹងអាជីវកម្មរបស់ម្ចាស់អាជ្ញាបណ្ណ ។

ជ-ផ្តល់ជូនក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យ បានទាន់ពេលវេលា ស្ថិតិ និងព័ត៌មានផ្សេងៗដែលទាក់ទងនឹងអាជីវកម្មទេសចរណ៍ តាមការស្នើសុំ និងការតម្រូវដោយក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិ ។

ឈ-ដាក់តាំងអាជ្ញាបណ្ណទេសចរណ៍ នៅទីកន្លែងដែលងាយមើលឃើញច្បាស់ក្នុងទីបរិវេណធ្វើអាជីវកម្មរបស់អ្នកទទួលអាជ្ញាបណ្ណ ។

ញ-ធានាថាលេខចុះបញ្ជី និងប្រភេទអាជ្ញាបណ្ណទេសចរណ៍ត្រូវបញ្ជាក់ រាល់ពេលសរសេរឆ្លើយឆ្លងជាមួយបណ្តាដៃគូពាក់ព័ន្ធ និងដៃគូអាជីវកម្ម ។

ចំពោះលក្ខខណ្ឌពិសេសផ្សេងៗទៀត ដែលតម្រូវសម្រាប់ប្រភេទអាជ្ញាបណ្ណនីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ។

មាត្រា ៤០.-

ភ្នាក់ងារទេសចរណ៍ និងការីទេសចរណ៍ ដើម្បីធានាដល់អាជីវកម្ម និង ការពារអតិថិជនត្រូវកក់ប្រាក់ធានាក្នុងធនាគារជាសាច់ប្រាក់ ឬ ជាការធានារបស់ធនាគារ តាមទំហំមួយដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ។

នីតិវិធី និងសេចក្តីតម្រូវលើការគ្រប់គ្រងប្រាក់កក់ធានា និងការផ្លាស់ប្តូរនៃប្រាក់កក់ធានាក្នុងធនាគារ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ។

មាត្រា ៤១.-

ប្រសិនបើ អ្នកស្នើសុំឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យ និងការតម្រូវដូចមានចែងក្នុងជំពូកទី ៥ នៃច្បាប់នេះ ក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវចេញអាជ្ញាបណ្ណដែលមានសុពលភាពអប្បបរមា ០១ (មួយ) ឆ្នាំ ដល់អ្នកស្នើសុំ ។

ប្រសិនបើ អ្នកស្នើសុំពុំបានបំពេញទៅតាមលក្ខខណ្ឌ ដូចមានចែងក្នុងជំពូកទី ៥ នៃច្បាប់នេះ ហើយបើក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិ យល់ព្រមទទួលយកការធានាជាលាយលក្ខណ៍អក្សរពីអ្នកស្នើសុំក្នុងការអនុវត្ត តាមលក្ខណៈវិនិច្ឆ័យ និងសេចក្តី

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

19/401

តម្រូវនោះ ក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិ អាចចេញនូវអាជ្ញាបណ្ណបណ្ដោះអាសន្នដែលមានសុពលភាពរយៈពេល ៩០ (កៅសិប) ថ្ងៃ ក្រោយពេលដែលអ្នកស្នើសុំបានបង់កម្រៃអាជ្ញាបណ្ណរួច ។

ក្នុងរយៈពេលកំណត់នៃកិច្ចសន្យា បើពិនិត្យឃើញថា ម្ចាស់អាជ្ញាបណ្ណបណ្ដោះអាសន្នបានអនុវត្តទៅតាមលក្ខណវិនិច្ឆ័យ និងការតម្រូវទាំងអស់រួចហើយ ក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវសម្រេចផ្ដល់ឱ្យនូវអាជ្ញាបណ្ណពេញសិទ្ធិដល់អ្នកស្នើសុំ ។ ផ្ទុយទៅវិញ ក្នុងករណីដែលអ្នកស្នើសុំមិនបានបំពេញតាមលក្ខខណ្ឌនៃកិច្ចសន្យា ហើយនៅតែបន្តធ្វើអាជីវកម្មលើអាជ្ញាបណ្ណបណ្ដោះអាសន្នដែលអស់សុពលភាព ត្រូវចាត់ទុកថាជាការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ ។

មាត្រា ៤២.-

ម្ចាស់អាជ្ញាបណ្ណ ត្រូវតែដាក់ពាក្យសុំបន្តអាជ្ញាបណ្ណឱ្យបាន ៣០ (សាមសិប) ថ្ងៃ យ៉ាងតិចមុនថ្ងៃផុតកំណត់សុពលភាពអាជ្ញាបណ្ណ ដោយភ្ជាប់មកជាមួយនូវប្រាក់កម្រៃអាជ្ញាបណ្ណ ព្រមទាំងឯកសារ និងព័ត៌មានផ្សេងៗដែលបានកំណត់នៅក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ។

មាត្រា ៤៣.-

អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ដែលចេញនៅក្រោមច្បាប់នេះ មិនអាចធ្វើការផ្ទេរ ឬ លក់បានទេ ដោយសារតែអាជ្ញាបណ្ណនេះផ្អែកលើគុណវុឌ្ឍិបុគ្គល និង បទពិសោធន៍របស់ម្ចាស់អាជ្ញាបណ្ណ ។

អាជ្ញាបណ្ណទេសចរណ៍ដទៃផ្សេងទៀតដែលចេញនៅក្រោមច្បាប់នេះអាចផ្ទេរ ឬ លក់ក្រោមលក្ខខណ្ឌដូចតទៅ :

ក-ម្ចាស់អាជ្ញាបណ្ណត្រូវដាក់ពាក្យសុំផ្ទេរ ឬ លក់អាជ្ញាបណ្ណមកក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិ តាមគំរូដែលបានកំណត់ និងដោយភ្ជាប់មកជាមួយនូវសោហ៊ុយសេវាផ្ទេរ ឬ លក់អាជ្ញាបណ្ណ ឯកសាររួមទាំងព័ត៌មានផ្សេងៗទៀតដែលកំណត់ដោយក្រសួងទេសចរណ៍ ។

ROYAUME DU CAMBODGE
MINISTERE DU PALAIS ROYAL

ខ-បុគ្គលជាអ្នកទទួលអាជ្ញាបណ្ណពីការផ្ទេរ ឬទិញអាជ្ញាបណ្ណត្រូវបំពេញរាល់លក្ខខណ្ឌតម្រូវស្តីពីការចេញអាជ្ញាបណ្ណរបស់ក្រសួងទេសចរណ៍ ដូចមានចែងក្នុងជំពូកទី ៥ នៃច្បាប់នេះ ។

គ-ការផ្ទេរ ឬ ការលក់អាជ្ញាបណ្ណទេសចរណ៍នេះអាចប្រព្រឹត្តទៅបាន លុះត្រាណាតែម្ចាស់អាជ្ញាបណ្ណបានបំពេញកាតព្វកិច្ចពន្ធ តាមច្បាប់ជាធរមាន និងបានដោះស្រាយរួចរាល់នូវបញ្ហាផ្សេងៗទៀត ជាមួយបណ្តាភាគីពាក់ព័ន្ធរបស់ខ្លួន ឬ បុគ្គលជាអ្នកទទួលអាជ្ញាបណ្ណពីការផ្ទេរ ឬ ការទិញអាជ្ញាបណ្ណ យល់ព្រមជាលាយលក្ខណ៍អក្សរបំពេញកាតព្វកិច្ចពន្ធ ឬ ដោះស្រាយបញ្ហាសេសសល់ទាំងនោះ លើកលែងតែមានកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរផ្សេងពីនេះ រវាងភាគីពាក់ព័ន្ធ ។

ឃ-ក្នុងករណីដែលអាជ្ញាបណ្ណជាអាជ្ញាបណ្ណបណ្តោះអាសន្ន បុគ្គលជាអ្នកទទួលអាជ្ញាបណ្ណពីការផ្ទេរ ឬ ការទិញអាជ្ញាបណ្ណ ត្រូវផ្តល់ជូនក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិនូវការយល់ព្រមជាលាយលក្ខណ៍អក្សរនៅក្នុងការបំពេញលក្ខខណ្ឌដែលនៅសល់ក្នុងរយៈពេលនៅសល់ ។

មាត្រា ៤៤.-

ប្រសិនបើក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិរកឃើញថា ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ បានផ្តល់ព័ត៌មានមិនពិតទាក់ទងទៅនឹងការដាក់ពាក្យសុំ ឬ ខកខានក្នុងការអនុវត្តតាមលក្ខខណ្ឌទាំងអស់ ឬ លក្ខខណ្ឌណាមួយនៃអាជ្ញាបណ្ណ ក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិអាចលុបចោលអាជ្ញាបណ្ណ ព្យួរអាជ្ញាបណ្ណ ឬ បញ្ចុះថ្នាក់អាជ្ញាបណ្ណនោះទៅជាអាជ្ញាបណ្ណបណ្តោះអាសន្ន ដោយធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរ ៣០ (សាមសិប) ថ្ងៃ ជាមុនទៅកាន់ម្ចាស់អាជ្ញាបណ្ណ ។ សេចក្តីជូនដំណឹងអំពីការលុប ការព្យួរ ឬ ការបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍នេះ ត្រូវមានបញ្ជាក់ហេតុផលច្បាស់លាស់ ។

នៅក្នុងស្ថានភាពបន្ទាន់ដែលក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិពិនិត្យឃើញថា ការបន្តប្រតិបត្តិការអាជីវកម្មទេសចរណ៍មួយ បង្កឱ្យមានហានិភ័យធ្ងន់ធ្ងរភ្លាមៗមកលើសុខុមាលភាព សុវត្ថិភាព ឬ សន្តិសុខ ក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិអាចលុប ឬ ព្យួរអាជ្ញាបណ្ណនោះជាបន្ទាន់ ដោយបញ្ជាក់ហេតុផលច្បាស់លាស់ ។

ការលុបចោល ការព្យួរ ឬ ការបញ្ចុះថ្នាក់អាជ្ញាបណ្ណ ដូចមានចែងក្នុងមាត្រានេះ មិនធ្វើឱ្យម្ចាស់អាជ្ញាបណ្ណរួចផុតពីការទទួលខុសត្រូវចំពោះបទល្មើស និង ទោសប្បញ្ញត្តិ ដែលមានកំណត់ក្នុងជំពូកទី ១០ នៃច្បាប់នេះ និងច្បាប់ជាធរមានដទៃទៀតឡើយ ។

លក្ខខណ្ឌ និងនីតិវិធីនៃការលុប ការព្យួរ ឬ ការបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍ មកជាអាជ្ញាបណ្ណបណ្តោះអាសន្ន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ។

មាត្រា ៤៥.-

ក្នុងករណី ដែលម្ចាស់អាជ្ញាបណ្ណទេសចរណ៍មិនបំពេញទៅតាមលក្ខណវិនិច្ឆ័យ ឬ ការតម្រូវផ្សេងៗ សម្រាប់អាជ្ញាបណ្ណដោយសារតែហេតុផលមរណភាពរបស់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ ឬ របស់អ្នកចាត់ការ ឬ ដោយហេតុផលស្របច្បាប់ដែលហួសពីការត្រួតត្រារបស់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ និងមានលក្ខណៈអាចទទួលយកបាន ក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិអាចផ្តល់អាជ្ញាបណ្ណទេសចរណ៍បណ្តោះអាសន្នដល់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ ទាយាទ ឬ បុគ្គលដែលមានការទទួលខុសត្រូវ នៅក្នុងការរំលាយក្រុមហ៊ុន ដើម្បីសម្រួល កែតម្រូវបញ្ហាតាមលំដាប់លំដោយ ឬ ដើម្បីផ្ទេរអាជីវកម្មនោះ ។

មាត្រា ៤៦.-

បុគ្គលណាម្នាក់ដែលគិតថា បានទទួលរងគ្រោះដោយសារសេចក្តីសម្រេចរបស់ក្រសួងទេសចរណ៍ ឬ របស់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីការបដិសេធ ការព្យួរ ការលុប ការបញ្ចុះថ្នាក់ ឬ ការសម្រេចដែលមានការពាក់ព័ន្ធផ្សេងៗដូចមានចែងក្នុងជំពូកទី ៥ នៃច្បាប់នេះ អាចធ្វើលិខិតតវ៉ាទៅរដ្ឋមន្ត្រីក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃបន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរស្តីពីការសម្រេចណាមួយ ដូចរៀបរាប់ខាងលើ ។

បន្ទាប់ពីបានទទួលលិខិតតវ៉ា ក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិ អាចធ្វើការព្យួរសេចក្តីសម្រេចរបស់ខ្លួន ហើយធ្វើការសម្រេចជាថ្មីឡើងវិញ ក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

Vrl

មាត្រា ៤៧.-

ក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរក្សាបញ្ជីអាជ្ញាបណ្ណទេសចរណ៍ ត្រូវបោះពុម្ពរាល់សេចក្តីសម្រេច រួមទាំងការបដិសេធ ការផ្តល់ឱ្យ ការលុបចោល ការព្យួរ ការបញ្ចុះថ្នាក់នៃអាជ្ញាបណ្ណទេសចរណ៍នៅក្នុងព្រឹត្តិបត្រ និង/ឬគេហទំព័ររបស់ខ្លួន ។

សាធារណជនអាចសុំពិនិត្យមើលបញ្ជីអាជ្ញាបណ្ណទេសចរណ៍ នៅក្រសួងទេសចរណ ឬ ទីស្នាក់ការរដ្ឋបាលថ្នាក់ក្រោមជាតិបានគ្រប់ពេលម៉ោងធ្វើការ និងអាចស្នើសុំថតចម្លងឯកសារនោះបាន ។

ជំពូកទី ៦

ភារកិច្ចរបស់ភាគីពាក់ព័ន្ធលើវិស័យទេសចរណ៍

មាត្រា ៤៨.-

ប្រតិបត្តិករទេសចរណ៍ រួមទាំងភ្នាក់ងារ និយោជិត និងអ្នកជាប់កិច្ចសន្យាទាំងអស់ ត្រូវមានកាតព្វកិច្ចដូចតទៅ :

ក-អនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ដែលពាក់ព័ន្ធនឹងស្តង់ដារ ក្រមប្រតិបត្តិវិជ្ជាជីវៈ ក្រមសីលធម៌វិជ្ជាជីវៈ និងលក្ខខណ្ឌនានានៃអាជ្ញាបណ្ណទេសចរណ៍ ។

ខ-អនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិទាំងឡាយ ដែលប៉ះពាល់ទៅលើ ឬ ទទួលរងការប៉ះពាល់ដោយវិស័យទេសចរណ៍ ដូចជាការកំណត់នគរូបនីយកម្ម ការសាងសង់អគារ សុវត្ថិភាព អគ្គិភ័យ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ បរិស្ថាន សុខភាព អនាម័យ ម្ហូបអាហារ ការងារ កាតព្វកិច្ចពន្ធ គណនេយ្យ និងហិរញ្ញវត្ថុ ការការពារ មរតកវប្បធម៌ មរតកធម្មជាតិ និងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

គ-ការពារប្រយោជន៍ជាតិ និងប្រយោជន៍ទេសចរ និងចូលរួមចំណែកនៅក្នុងការថែរក្សាធនធានធម្មជាតិ មិនបំពុល ឬ មិនបំផ្លាញបរិស្ថាន ការពារនិងអភិរក្សមរតកវប្បធម៌ សិល្បៈ ប្រពៃណី ទំនៀមទម្លាប់ របស់ប្រជាពលរដ្ឋខ្មែរក្នុងរាល់សកម្មភាពទេសចរណ៍របស់ខ្លួន ។

ឃ-ផ្តល់ដល់ទេសចរនូវព័ត៌មានពិតច្បាស់លាស់ និងទទួលខុសត្រូវផ្តល់សេវាកម្ម

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ព្រះបរមរាជវាំង

ដូចដែលបានសន្យា ព្រមទាំងមានវិធានការសមស្របដើម្បីថែទាំទ្រព្យសម្បត្តិ ការពារសន្តិសុខ និងសុវត្ថិភាពដល់ទេសចរក្នុងពេលដែលទេសចរស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន ។

ង-ប្តឹង ឬ រាយការណ៍ជាបន្ទាន់ទៅនគរបាលទេសចរណ៍ អាជ្ញាធរមានសមត្ថកិច្ច ឬ សមត្ថកិច្ចទេសចរណ៍ដែលនៅជិតបំផុត ក្នុងករណីដឹង ឬ មានការសង្ស័យថា មានការប្រព្រឹត្តបទល្មើស ការជួញដូរ និង ការប្រើប្រាស់គ្រឿងញៀន ការជួញដូរនិងការបង្ខាំងមនុស្ស ការជួញដូរកុមារ ការធ្វើអាជីវកម្មផ្លូវភេទ ការផ្សព្វផ្សាយរូបភាព និង សម្ភារៈអាសអាភាស ឬ ប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌផ្សេងៗទៀត ។

ច-អ្នកគ្រប់គ្រងសណ្ឋាគារ ឬ សេវាកម្មស្នាក់នៅទេសចរណ៍ ត្រូវកត់ត្រាទុកអត្តសញ្ញាណរបស់អតិថិជន និងព័ត៌មានផ្សេងៗទៀតនៅពេលចូលស្នាក់នៅ ។

ឆ-សហការនៅក្នុងកិច្ចការអធិការកិច្ច ដូចមានចែងក្នុងមាត្រា ៦០ នៃច្បាប់នេះ ។

ជ-ប្រតិបត្តិស្របតាមក្រមសីលធម៌វិជ្ជាជីវៈរបស់អង្គការទេសចរណ៍ពិភពលោកឱ្យបានល្អ ។

ឈ-អនុវត្តឱ្យបានខ្ជាប់ខ្ជួននូវលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៣៩ និងលក្ខខណ្ឌដទៃផ្សេងទៀតដែលមានចែងក្នុងជំពូកទី ៥ នៃច្បាប់នេះ ។

មាត្រា ៤៩.-

មន្ត្រីមានសមត្ថកិច្ចដែលពាក់ព័ន្ធនឹងវិស័យទេសចរណ៍ ត្រូវមានកាតព្វកិច្ច ដូចតទៅ :

ក-ផ្តល់ដល់ទេសចរនូវព័ត៌មានឥតលាក់លៀម និងមិនលំអៀង ។

ខ-ជួយយកអាសាដោយភាពស្មោះត្រង់ និងផ្តល់ភាពរាក់ទាក់ក្នុងនាមជាម្ចាស់ផ្ទះ ។

គ-សម្រួលការធ្វើដំណើរដល់ទេសចរ សម្រួលកិច្ចការលិខិតស្នាម និង បែបបទនានាឱ្យសាមញ្ញ ។

ឃ-មិនរើសអើងសញ្ជាតិ ពូជសាសន៍ ពណ៌សម្បុរ និងសាសនា ។

ង-ចាត់វិធានការចាំបាច់ ដើម្បីការពារថែរក្សាទ្រព្យសម្បត្តិរបស់ទេសចរ និងសន្តិសុខ សុវត្ថិភាព ។

ROYAUME DU CAMBODGE ... ROYAL

ច-ប្រតិបត្តិស្របតាមក្រមសីលធម៌វិជ្ជាជីវៈរបស់អង្គការទេសចរណ៍ពិភពលោកឱ្យ បានល្អ ។

មាត្រា ៥០.-

ទេសចរ ឬ អ្នកធ្វើដំណើរកម្សាន្តត្រូវមានកាតព្វកិច្ចដូចតទៅ :

ក-គោរពច្បាប់ និងបទប្បញ្ញត្តិជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា ។

ខ-គោរពប្រពៃណី ទំនៀមទម្លាប់ និងវប្បធម៌ខ្មែរ និងមិនត្រូវចូលរួមក្នុងសកម្មភាពណាមួយដែលបំពាន ឬ ធ្វើឱ្យខូចដល់វប្បធម៌ខ្មែរ ។

គ-មិនត្រូវធ្វើឱ្យខូចខាតដល់បរិស្ថាន ឬ មរតកវប្បធម៌ និងមរតកធម្មជាតិ ។

ឃ-មិនត្រូវចូលរួមក្នុងសកម្មភាពណាមួយដែលពាក់ព័ន្ធដល់ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀន ការជួញដូរនិងការបង្ខាំងមនុស្ស ការជួញដូរកុមារ ការធ្វើអាជីវកម្មផ្លូវភេទ ការផ្សព្វផ្សាយរូបភាព និង សម្ភារៈអាសអាភាស ការលាងលុយកខ្វក់ និងការបង្កឱ្យមានអសន្តិសុខក្នុងសង្គម ។

ង-មិនធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គម និងសុខុមាលភាពជាទូទៅ ។

ច-មិនត្រូវគំរាមកំហែងដល់សន្តិសុខ ឬ ជាប់ពាក់ព័ន្ធដល់ក្រុមភេរវកម្ម ។

ឆ-អនុវត្តឱ្យ បានខ្ជាប់ខ្ជួននូវក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈដែលចេញដោយក្រសួងទេសចរណ៍ ឬ ដែលបង្កើតឡើងដោយសមាគមឧស្សាហកម្មទេសចរណ៍ ហើយយល់ព្រមដោយក្រសួងទេសចរណ៍ ។

ជ-ប្រតិបត្តិស្របតាមក្រមសីលធម៌វិជ្ជាជីវៈរបស់អង្គការទេសចរណ៍ពិភពលោកឱ្យ បានល្អ ។

ឈ-ចំពោះទេសចរ ឬ អ្នកធ្វើដំណើរកម្សាន្តជាជនបរទេសមិនត្រូវប្រើប្រាស់ទិសដៅទេសចរណ៍ ជាឱកាសដើម្បីស្វែងរកការងារ ឬ ការតាំងលំនៅឋាន ។

មាត្រា ៥១.-

ក្រសួងទេសចរណ៍ត្រូវរៀបចំបង្កើត និងបំផុសឱ្យ មានការបង្កើតក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរ អ្នកពាក់ព័ន្ធ សមាគម ឧស្សាហកម្មទេសចរណ៍ និងអ្នកដែលពាក់ព័ន្ធផ្សេងៗទៀត ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

មាត្រា ៥២.-

ក្រសួងទេសចរណ៍អាចផ្ទេរការទទួលខុសត្រូវ ចំពោះការបង្កើតក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈ ទៅឱ្យសមាគមឧស្សាហកម្មទេសចរណ៍ដែលពាក់ព័ន្ធ នៅពេលដែលសមាគមឧស្សាហកម្មទេសចរណ៍នោះ ត្រូវបានបង្កើតឡើងដោយមានតំណាងគ្រប់គ្រាន់ និងមានប្រសិទ្ធភាព ។ ប្រសិនបើក្រសួងទេសចរណ៍ស្នើឱ្យសមាគមឧស្សាហកម្មទេសចរណ៍បង្កើត ឬ ធ្វើឱ្យប្រសើរនូវក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈ សមាគមឧស្សាហកម្មទេសចរណ៍ត្រូវទទួលធ្វើការងារនេះ ដោយពិគ្រោះយោបល់ជាមួយសមាជិករបស់ខ្លួន និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ហើយដាក់ឆ្នងសេចក្តីព្រាងក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈនោះទៅក្រសួងទេសចរណ៍ ដើម្បីពិនិត្យ និងសម្រេច ។

មាត្រា ៥៣.-

ក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈដែលចេញដោយក្រសួងទេសចរណ៍ ត្រូវភ្ជាប់កាតព្វកិច្ចលើអ្នកដែលពាក់ព័ន្ធ ហើយអាចប្រើជាលក្ខខណ្ឌសម្រាប់ការចេញអាជ្ញាបណ្ណទេសចរណ៍តាមការស្នើសុំរបស់ក្រសួងទេសចរណ៍ ។

ក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈដែលបានបង្កើតឡើងដោយសមាគមឧស្សាហកម្មទេសចរណ៍ និងយល់ព្រមដោយក្រសួងទេសចរណ៍ ត្រូវភ្ជាប់កាតព្វកិច្ចលើសមាជិករបស់ខ្លួន ហើយសមាគមត្រូវចាត់វិធានការសមស្រប ដើម្បីធានាឱ្យសមាជិករបស់ខ្លួនអនុវត្តតាម ។

ជំពូកទី ៧
ការដោះស្រាយវិវាទទេសចរណ៍

មាត្រា ៥៤.-

ក្រសួងទេសចរណ៍ត្រូវរៀបចំបង្កើតគណៈកម្មការមួយហៅថា **"គណៈកម្មការដោះស្រាយវិវាទទេសចរណ៍"** ដើម្បីសម្របសម្រួល ដោះស្រាយវិវាទ និង ការប្រតិបត្តិតាមកាតព្វកិច្ចក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ ។

រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ត្រូវចេញប្រកាសដើម្បីផ្សព្វផ្សាយអំពីប្រភេទនៃវិវាទនានា ដែលក្រសួងមានតួនាទីជាអ្នកទទួលដោះស្រាយ ។

មាត្រា ៥៥.–

ប្រភេទវិវាទដែលក្រសួងទេសចរណ៍ មានតួនាទីជាអ្នកទទួលសម្របសម្រួល និងដោះស្រាយ រួមមានវិវាទរវាងប្រតិបត្តិករអាជីវកម្មទេសចរណ៍ ភ្នាក់ងាររបស់គេ និយោជិត អ្នកជាប់កិច្ចសន្យា មន្ត្រីសមត្ថកិច្ចដែលពាក់ព័ន្ធនឹងទេសចរណ៍ ទេសចរ និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ។

គណៈកម្មការដោះស្រាយវិវាទទេសចរណ៍ ត្រូវពិចារណាដោះស្រាយវិវាទប្រកបដោយយុត្តិធម៌ ។ ប្រសិនបើគណៈកម្មការមិនអាចដោះស្រាយវិវាទនោះបានទេ ភាគីណាមួយអាចបន្តរឿងក្តីនោះទៅតុលាការដើម្បីរកដំណោះស្រាយតាមផ្លូវច្បាប់ ។

ការចំណាយ និងសោហ៊ុយរបស់គណៈកម្មការដោះស្រាយវិវាទទេសចរណ៍ ត្រូវកំណត់ដោយប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ជំពូកទី ៨
ការហាមឃាត់អនីតិជន

មាត្រា ៥៦.–

អនីតិជនមិនត្រូវបានអនុញ្ញាត ឱ្យចូលទៅកាន់ទីបរិវេណមណ្ឌលកម្សាន្តទេសចរណ៍សម្រាប់មនុស្សពេញវ័យឡើយ ។

មាត្រា ៥៧.–

អ្នកគ្រប់គ្រង និងម្ចាស់អាជ្ញាបណ្ណនៃមណ្ឌលកម្សាន្តទេសចរណ៍សម្រាប់មនុស្សពេញវ័យត្រូវហាមឃាត់ និងចាត់វិធានការសមស្របដើម្បីធានាថា មិនមានវត្តមានអនីតិជននៅក្នុងទីបរិវេណនោះ និងត្រូវត្រួតពិនិត្យផ្ទៀងផ្ទាត់អត្តសញ្ញាណបណ្ណអតិថិជនវ័យក្មេងទាំងអស់ដើម្បីធានាឱ្យមានការប្រតិបត្តិតាមកាតព្វកិច្ចក្រោមមាត្រានេះ ។

បែបបទនៃការអនុវត្តមាត្រា ៥៦ និងមាត្រា ៥៧ នៃច្បាប់នេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

ជំពូកទី ៩
ការអង្កេត អធិការកិច្ច និងការអនុវត្តច្បាប់

មាត្រា ៥៨.-

ក្រសួងទេសចរណ៍ត្រូវដឹកនាំការងារអធិការកិច្ច :

ក-បញ្ជូនមន្ត្រីចុះត្រួតពិនិត្យ ធ្វើអធិការកិច្ចលើទីកន្លែងប្រកបអាជីវកម្ម លើទីបរិវេណ ឬ សម្ភារៈដែលបានប្រើប្រាស់ ឬ សង្ស័យថាបានប្រើប្រាស់សម្រាប់គោលបំណងអាជីវកម្មទេសចរណ៍ និងដែលបានប្រើប្រាស់ ឬ ដែលបានសង្ស័យថាបានប្រើប្រាស់ផ្ទុយនឹងច្បាប់ ។ ក្នុងការធ្វើអធិការកិច្ច ក្រសួងទេសចរណ៍អាចសហការ និងសម្របសម្រួលជាមួយមន្ត្រីពីក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចផ្សេងៗទៀត ។

ខ-ប្រសិនបើទីបរិវេណប្រកបអាជីវកម្មនោះ ត្រូវបានប្រើប្រាស់ជាលំនៅឋានផងដែរ ការធ្វើអធិការកិច្ចអាចប្រព្រឹត្តទៅបានតែក្នុងអំឡុងម៉ោងអាជីវកម្មប៉ុណ្ណោះ ។

មាត្រា ៥៩.-

មន្ត្រីអធិការកិច្ចត្រូវបង្ហាញអត្តសញ្ញាណបណ្ណមុខងារ និងបណ្ណបេសកកម្ម ឬ លិខិតអនុញ្ញាតឱ្យបំពេញបេសកកម្មមុនចាប់ផ្តើមធ្វើអធិការកិច្ច ។មន្ត្រីអធិការកិច្ចទេសចរណ៍ត្រូវមាននីតិសម្បទាជានគរបាលយុត្តិធម៌ ។

មាត្រា ៦០.-

ម្ចាស់អាជ្ញាបណ្ណ ប្រតិបត្តិករទេសចរណ៍ និងបុគ្គលដែលកាន់កាប់ទីកន្លែងប្រកបអាជីវកម្ម ទីបរិវេណ ឬ សម្ភារៈបរិក្ខារជាកម្មវត្ថុនៃអធិការកិច្ច ត្រូវសហការជាមួយមន្ត្រីអធិការកិច្ចទេសចរណ៍ដោយផ្តល់ព័ត៌មានត្រឹមត្រូវពិតប្រាកដ គ្រប់គ្រាន់ និងការពន្យល់បកស្រាយរាល់ការចោទសួរណាមួយ ដើម្បីធានាឱ្យមន្ត្រីអធិការកិច្ច អាចអនុវត្តភារកិច្ចបាន ។ គ្មានបុគ្គលណាម្នាក់អាចរារាំង បង្អាក់ ឬ ជ្រៀតជ្រែកក្នុងការងារអធិការកិច្ចដែលមានចែងក្នុងច្បាប់នេះឡើយ ។

មាត្រា ៦១.-

ប្រសិនបើមន្ត្រីអធិការកិច្ចពិនិត្យឃើញថាមានការរំលោភបទប្បញ្ញត្តិនៃច្បាប់នេះ មន្ត្រីអធិការកិច្ចនោះអាចចាត់វិធានការតាមច្បាប់នេះ និងក្នុងករណីចាំបាច់ ត្រូវស្នើសុំឱ្យមានកិច្ចសហការពីសមត្ថកិច្ចពាក់ព័ន្ធ ។ បើជាករណីធ្ងន់ធ្ងរត្រូវរាយការណ៍ ជាបន្ទាន់ជូនក្រសួងទេសចរណ៍ដើម្បីចាត់វិធានការតាមច្បាប់ ។

ក្នុងករណីដែលពិនិត្យឃើញ ឬ មានហេតុផលជាមូលដ្ឋានអាចជឿជាក់ថាមានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ មន្ត្រីអធិការកិច្ចនោះត្រូវរាយការណ៍ជាបន្ទាន់ជូនព្រះរាជអាជ្ញា ឬ មន្ត្រីនគរបាលយុត្តិធម៌មានសមត្ថកិច្ចនៃតំបន់ពាក់ព័ន្ធនោះ ដើម្បីចាត់វិធានការតាមនីតិវិធីនៃច្បាប់ ។

មាត្រា ៦២.-

ក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិចាត់វិធានការចាំបាច់ ដើម្បីបញ្ឈប់ជាបន្ទាន់ និងបិទអាជីវកម្មណាដែលអាជ្ញាបណ្ណរបស់អាជីវកម្មនោះ ត្រូវបានលុបចោល ឬ ព្យួរ ឬ អាជីវកម្មណាដែលគ្មានអាជ្ញាបណ្ណទេសចរណ៍ ។

ជំពូកទី ១០

ទោសប្បញ្ញត្តិ

មាត្រា ៦៣.-

ការពិន័យអន្តរការណ៍ ដែលកំណត់ដោយច្បាប់នេះ ត្រូវធ្វើដោយមន្ត្រីអធិការកិច្ចទេសចរណ៍ និង/ឬនគរបាលទេសចរណ៍ ។ នីតិវិធី និងលក្ខខណ្ឌក្នុងការពិន័យអន្តរការណ៍ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ។

ការបែងចែកសមត្ថកិច្ចរវាងមន្ត្រីអធិការកិច្ចទេសចរណ៍ និងនគរបាលទេសចរណ៍ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

មាត្រា ៦៤.-

ការដាក់ពិន័យអន្តរការណ៍ មិនធ្វើឱ្យអ្នកប្រព្រឹត្តអំពើនោះរួចផុតពីការទទួលខុសត្រូវខាងរដ្ឋប្បវេណី និង/ឬការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ដែលមានចែងដោយច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

មាត្រា ៦៥.-

បុគ្គលណាដែលប្រកបអាជីវកម្មទេសចរណ៍ដោយគ្មានអាជ្ញាបណ្ណទេសចរណ៍ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ ដែលអប្បបរមាស្មើនឹង ២.០០០.០០០ (ពីរលាន) រៀល និងអតិបរមាមិនលើសពី ២០.០០០.០០០ (ម្ភៃលាន) រៀល ។ ទំហំទឹកប្រាក់នៃការពិន័យអន្តរការណ៍សម្រាប់ប្រភេទអាជីវកម្មទេសចរណ៍នីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ។

មាត្រា ៦៦.-

ការប្រព្រឹត្តរំលោភលើកាតព្វកិច្ច ដូចមានចែងក្នុងមាត្រា ៤៨ នៃច្បាប់នេះ អាចជាកម្មវត្ថុនៃការពិន័យអន្តរការណ៍ ។ អំពើដែលជាកម្មវត្ថុ និងទំហំទឹកប្រាក់នៃការពិន័យអន្តរការណ៍នេះ ត្រូវកំណត់លំអិតដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ។

មាត្រា ៦៧.-

មន្ត្រីមានសមត្ថកិច្ចដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មខាងរដ្ឋបាល ដោយមិនទាន់គិតពីទណ្ឌកម្មផ្សេងទៀតស្របតាមច្បាប់ និង បទប្បញ្ញត្តិជាធរមានឡើយ ។

មាត្រា ៦៨.-

ទេសចរ ឬ អ្នកធ្វើដំណើរកម្សាន្តដែលប្រព្រឹត្តល្មើសនឹងមាត្រា ៥០ នៃច្បាប់នេះ អាចត្រូវលុបចោលទិដ្ឋាការទេសចរណ៍ ហើយបណ្តេញចេញ ឬ ហាមឃាត់វត្តមានក្នុងតំបន់គោលដៅទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេលកំណត់ណាមួយ ដែលមិនលើសពី ០៥ (ប្រាំ) ឆ្នាំ ឬ ជាអចិន្ត្រៃយ៍ ។

ROYAUME DU CAMBODGE
ព្រះរាជរដ្ឋាភិបាល
...S ROYAL

មាត្រា ៦៩.-

ទេសចរ ឬ អ្នកធ្វើដំណើរកម្សាន្ត ដែលធ្វើឱ្យខូចខាតដល់បរិស្ថាន មរតកវប្បធម៌ ឬ មរតកធម្មជាតិ ត្រូវទទួលខុសត្រូវតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

មាត្រា ៧០.-

អ្នកគ្រប់គ្រង ឬ ម្ចាស់មណ្ឌលកម្សាន្តទេសចរណ៍សម្រាប់មនុស្សពេញវ័យ ដែលប្រព្រឹត្តល្មើសនឹងមាត្រា ៥៧ នៃច្បាប់នេះ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ដល់ ១០.០០០.០០០ (ដប់លាន) រៀល ដោយមិនទាន់គិតដល់វិធានការរដ្ឋបាលផ្សេងទៀត ក្នុងករណីមិនរាងចាលត្រូវពិន័យជាប្រាក់ទ្វេដង ។

មាត្រា ៧១.-

ប្រតិបត្តិករទេសចរណ៍ដែលមិនអនុញ្ញាត ឬ រារាំងមន្ត្រីអធិការកិច្ចទេសចរណ៍បំពេញការងាររបស់ខ្លួនដូចមានចែងក្នុងច្បាប់នេះ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ដល់ ១០.០០០.០០០ (ដប់លាន) រៀល ដោយមិនទាន់គិតដល់វិធានការរដ្ឋបាលផ្សេងទៀត ក្នុងករណីមិនរាងចាលត្រូវពិន័យជាប្រាក់ទ្វេដង ។

មាត្រា ៧២.-

ជនណាដែលបង្កឱ្យមានការប្រព្រឹត្តល្មើស ឬ ការពារអាជីវកម្មទេសចរណ៍ ដែលប្រព្រឹត្តរំលោភនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវប្រឈមនឹងទណ្ឌកម្មខាងរដ្ឋបាល ឬ ការទទួលខុសត្រូវខាងព្រហ្មទណ្ឌ និងសំណងរដ្ឋប្បវេណីដែលមានចែងដោយច្បាប់ និង បទប្បញ្ញត្តិជាធរមានផ្សេងទៀត ។

មាត្រា ៧៣.-

ជនណាដែលបន្លំ ឬ បោកបញ្ឆោតក្នុងការលក់ផលិតផល ឬ សេវាកម្មទេសចរណ៍ក្លែងក្លាយដល់ភ្ញៀវ ត្រូវទទួលពិន័យអន្តរការណ៍ដែលមានចំនួនទ្វេដងនៃថ្លៃលក់ផលិតផល ឬ សេវាកម្មទេសចរណ៍ ។ ប្រសិនបើអំពើនោះបង្កើតជាបទល្មើសព្រហ្មទណ្ឌ ត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។ ក្នុងករណីនេះ ក្រសួងទេសចរណ៍អាចលុបចោល ឬ ព្យួរ ឬ បញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍មកជាអាជ្ញាបណ្ណបណ្តោះអាសន្ន ។

មាត្រា ៧៤.-

ជនណាដែលក្លែងអាជ្ញាបណ្ណទេសចរណ៍ ឬ ឯកសារសាធារណៈផ្សេងៗ ត្រូវផ្ដន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។

ជំពូកទី ១១

អន្តរប្បញ្ញត្តិ

មាត្រា ៧៥.-

អាជ្ញាបណ្ណទេសចរណ៍ ដែលចេញដោយក្រសួងទេសចរណ៍ មុនច្បាប់នេះចូលជាធរ-មាន នៅតែមានសុពលភាព និងប្រសិទ្ធភាពរហូតដល់ថ្ងៃអស់សុពលភាព ដូចដែលបានកំណត់នៅលើអាជ្ញាបណ្ណទេសចរណ៍នោះ ។

ប្រតិបត្តិករទេសចរណ៍ទាំងឡាយណា ដែលបើកដំណើរការអាជីវកម្មបម្រើសេវាកម្មទេសចរណ៍ដោយគ្មានអាជ្ញាបណ្ណទេសចរណ៍ ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ក្នុងរយៈពេល ០៣ (បី) ខែ បន្ទាប់ពីច្បាប់នេះចូលជាធរមាន ។

ជំពូកទី ១២

អវសានប្បញ្ញត្តិ

មាត្រា ៧៦.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៧៧.-

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩

នស/រកម.០៦០៩.០១៤

ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្ដលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
រដ្ឋមន្ត្រីក្រសួងទេសចរណ៍
ហត្ថលេខា

ថោង ខុន

បានចម្លងត្រឹមត្រូវ លេខ ៥៨៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

32/40

ឧបសម្ព័ន្ធ

និយមន័យនៃពាក្យ និងវាក្យស័ព្ទមួយចំនួនដែលប្រើក្នុងច្បាប់នេះ មានដូចតទៅ:

- **ការលើកទឹកចិត្ត** : សំដៅដល់រង្វាន់ដែលផ្តល់ដោយក្រសួងទេសចរណ៍ក្រោម មាត្រា ២៦ សម្រាប់ជាការលើកទឹកចិត្តដល់បណ្ណាអាជីវកម្មទេសចរណ៍ ឬ បុគ្គលដែលមាន ស្នាដៃ ក្នុងការរៀបចំបានល្អពិសេសៗនូវផលិតផល ឬ សេវាកម្មទេសចរណ៍ ហើយឆ្លើយតប តាមស្តង់ដារធានាគុណភាពផលិតផល ឬ សេវាកម្មទេសចរណ៍ ។

- **ការទទួលខុសត្រូវចម្បង** : សំដៅដល់សមត្ថកិច្ចគ្រប់គ្រងផ្ទាល់របស់ក្រសួងទេស- ចរណ៍ក្នុងការទទួលខុសត្រូវដឹកនាំគ្រប់គ្រងកិច្ចអភិវឌ្ឍផ្នែកសំខាន់ៗនៃឧស្សាហកម្មទេសចរណ៍ និងដឹកនាំចេញបទប្បញ្ញត្តិគ្រប់គ្រង និងផ្តល់អាជ្ញាបណ្ណទេសចរណ៍ ដូចមានចែងក្នុងមាត្រា ១០ មាត្រា ៣០ (ក) ក្រោមជំពូកទី ៣ និងជំពូកទី ៥ នៃច្បាប់ស្តីពីទេសចរណ៍ ។

- **ការទទួលខុសត្រូវរួមគ្នា** : សំដៅដល់សមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងទេសចរណ៍ ដែលត្រូវសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធក្នុងការទទួលខុសត្រូវគ្រប់គ្រង រួមគ្នានូវបណ្តាផ្នែកដែលប៉ះពាល់ទៅលើ ឬ ទទួលរងការប៉ះពាល់ដោយឧស្សាហកម្មទេស- ចរណ៍ ដោយចេញបទប្បញ្ញត្តិរួមគ្នាដើម្បីបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង ដូចមានចែងក្នុង មាត្រា ១១ មាត្រា ៣០ (ខ) ក្រោមជំពូកទី ៣ និងជំពូកទី ៥ នៃច្បាប់ស្តីពីទេសចរណ៍ ។

- **ការទទួលខុសត្រូវដោយផ្តល់យោបល់** : សំដៅដល់ការទទួលខុសត្រូវរបស់ក្រសួង ទេសចរណ៍ ក្នុងការធានាឱ្យបាននូវនិរន្តរភាពនៃការអភិវឌ្ឍវិស័យទេសចរណ៍ ដោយធ្វើការ ផ្តល់យោបល់ផ្នែកជំនាញទេសចរណ៍ជូនក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធដែលការងារ របស់គេប៉ះពាល់ទៅលើ ឬ ទទួលរងការប៉ះពាល់ដោយឧស្សាហកម្មទេសចរណ៍ដូចមាន កំណត់ក្នុងមាត្រា ១២ មាត្រា ៣០ (គ) ក្រោមជំពូកទី ៣ និង ជំពូកទី ៥ នៃច្បាប់ស្តីពីទេស- ចរណ៍ ។

- **ការទទួលស្គាល់គុណភាព** : សំដៅដល់វិញ្ញាបនបត្រដែលចេញដោយក្រសួង ទេសចរណ៍ ឬ ដែលចេញដោយសមាគមឧស្សាហកម្មទេសចរណ៍ ដើម្បីបញ្ជាក់ ទទួលស្គាល់ គុណភាពផលិតផល ឬ សេវាកម្មទេសចរណ៍ដែលបានឆ្លើយតបទៅនឹងស្តង់ដារធានាគុណ- ភាពកំណត់ដោយក្រសួងទេសចរណ៍ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

- **ការីទេសចរណ៍** : សំដៅដល់បុគ្គលដែលរៀបចំ និងលក់ខ្សែទស្សនកិច្ចព្រមទាំងប្រមូលផ្តុំសេវាកម្មទេសចរណ៍ផ្សេងៗទៀត សម្រាប់លក់ដោយផ្ទាល់ ឬ តាមរយៈភ្នាក់ងារទេសចរណ៍ ឬភាគីផ្សេងទៀតក្នុងកិច្ចសន្យា ។

- **កម្រៃអាជ្ញាបណ្ណទេសចរណ៍** : សំដៅដល់ប្រាក់ដែលត្រូវបង់ដើម្បីទទួលបានអាជ្ញាបណ្ណទេសចរណ៍ពីក្រសួងទេសចរណ៍ ឬ ពីរដ្ឋបាលថ្នាក់ក្រោមជាតិ ។

- **ក្រមប្រតិបត្តិវិជ្ជាជីវៈ** : សំដៅដល់បញ្ញត្តិដែលត្រូវបានកំណត់ឡើងសម្រាប់ប្រភេទវិជ្ជាជីវៈនីមួយៗនៃឧស្សាហកម្មទេសចរណ៍ ដែលមានចរិតលក្ខណៈជាការកម្រិត ឬ តម្រូវរួមទាំងការពិន័យចំពោះអ្នកដែលបានប្រព្រឹត្តផ្ទុយ មិនបានគោរពអនុវត្តវិជ្ជាជីវៈដែលខ្លួនកំពុងអនុវត្តនោះ ។

- **ក្រមសីលធម៌វិជ្ជាជីវៈ** : សំដៅដល់ច្បាប់ទំនួន ដែលត្រូវបានកំណត់ឡើងសម្រាប់ប្រភេទវិជ្ជាជីវៈនីមួយៗនៃឧស្សាហកម្មទេសចរណ៍ មានចរិតលក្ខណៈជាអភិសមាចារដោយភ្ជាប់ជាមួយនូវការអប់រំ តម្រែតម្រង់ និងពន្យល់ណែនាំប្រតិបត្តិករទេសចរណ៍ ក្នុងគោលបំណងលើកកំពស់ចរិយាមារយាទល្អប្រពៃ ការគោរពអនុវត្តសីលធម៌វិជ្ជាជីវៈ ។

- **ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា** : សំដៅដល់នីតិបុគ្គលមានលក្ខណៈជាដៃគូរវាងផ្នែកឯកជន និងផ្នែកសាធារណៈ ដែលបង្កើតឡើងដើម្បីពង្រឹង ពង្រីក និងអនុវត្តឱ្យមានប្រសិទ្ធភាពសកម្មភាពការងារសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា ។

- **ខ្សែទស្សនកិច្ច** : សំដៅដល់កញ្ចប់សេវាកម្មទេសចរណ៍រៀបចំឡើងដោយការីទេសចរណ៍រួមបញ្ចូលនូវសេវាកម្មយ៉ាងតិចពីរ ក្នុងចំណោមសេវាកម្មចាំបាច់ ដូចជាសេវាកម្មស្នាក់នៅទេសចរណ៍ សេវាកម្មដឹកជញ្ជូន សេវាកម្ម ម្ហូបអាហារ និងភេសជ្ជៈ ការធ្វើទស្សនកិច្ច សេវាកម្មមគ្គុទ្ទេសក៍ទេសចរណ៍ និងសេវាផ្សេងទៀតដែលពាក់ព័ន្ធ ដោយមានថ្លៃលក់មួយជាក់លាក់ និងស្ថិតក្នុងថេរវេលាប្រតិបត្តិជាកំណត់ ។

- **គោលបំណងទេសចរណ៍** : សំដៅដល់គោលបំណងសំខាន់ៗ ដូចជាសម្រាក លំហែកម្សាន្ត ទស្សនា សាសនា សកម្មភាពកីឡា ធុរកិច្ច សាកសួរសុខទុក្ខញាតិសន្តាន ព្យាបាលសុខភាព សិក្សាស្រាវជ្រាវ និងគោលបំណងទេសចរណ៍ស្របច្បាប់ផ្សេងៗទៀត ។

- **គោលដៅទាក់ទាញទេសចរណ៍** : សំដៅដល់ទីកន្លែងដែលមានភាពទាក់ទាញទេសចរណ៍ មានសម្បទាទេសចរណ៍ មានសេវាបម្រើប្រកបដោយផាសុកភាព និងមានលទ្ធភាពអាចចូលទៅដល់បាន ។

- **គណៈកម្មការដោះស្រាយវិវាទទេសចរណ៍** : សំដៅដល់អង្គការចាត់តាំងមួយដែលក្រសួងទេសចរណ៍ ត្រូវបង្កើតឡើងដោយផ្អែកលើសេចក្ដីត្រូវការ ដើម្បីទទួលសម្របសម្រួលដោះស្រាយវិវាទ និងការប្រតិបត្តិតាមកាតព្វកិច្ច ក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីទេសចរណ៍ ។

- **គ្រឹះស្ថានសិក្សាទេសចរណ៍ និងបដិសណ្ឋារកិច្ច** : សំដៅដល់គ្រឹះស្ថានសិក្សាជាសកលវិទ្យាល័យ មហាវិទ្យាល័យ វិទ្យាស្ថានដែលបង្កើតឡើងដោយផ្នែកសាធារណៈ ផ្នែកឯកជន ចម្រុះរដ្ឋ ឬ អង្គការមិនមែនរដ្ឋាភិបាលដែលមានការអប់រំបណ្ដុះបណ្ដាលជំនាញទេសចរណ៍ សណ្ឋាគារ និងបដិសណ្ឋារកិច្ច ។

- **តំបន់ទេសចរណ៍** : សំដៅដល់តំបន់ទាំងឡាយក្នុងព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានជ្រើសរើស រៀបចំ និងអភិវឌ្ឍបម្រើឱ្យគោលបំណង និងសកម្មភាពទេសចរណ៍ ។

- **ទេសចរណ៍** : សំដៅដល់សកម្មភាពទាំងឡាយរបស់បុគ្គល ដែលធ្វើដំណើរទៅ និងស្នាក់នៅកន្លែងផ្សេង ក្រៅពីបរិយាកាសប្រក្រតីរបស់គេ សម្រាប់រយៈពេលកំណត់មួយ ដែលមិនលើសពីមួយឆ្នាំជាប់ៗគ្នា ដើម្បីសម្រាក លំហែ កម្សាន្ដ ធុរកិច្ច និងគោលបំណងទេសចរណ៍ស្របច្បាប់ផ្សេងៗទៀត ។

- **ទេសចរ** : សំដៅដល់បុគ្គលទាំងឡាយ ជាជនជាតិកម្ពុជា ឬ ជនបរទេសដែលមកដល់តំបន់ផ្សេង ក្រៅពីបរិយាកាសប្រក្រតីរបស់គេ ស្នាក់នៅទីនោះចាប់ពីមួយយប់ឡើងទៅ និងមិនលើសពីរយៈពេលដែលកំណត់ដើម្បីសម្រាកលំហែ កម្សាន្ដ ធុរកិច្ច និងគោលបំណងទេសចរណ៍ស្របច្បាប់ផ្សេងៗទៀត ព្រមទាំងមិនទាក់ទងដល់គោលបំណងតាំងទីលំនៅ ឬ ធ្វើសកម្មភាពណាមួយដែលទទួលបានប្រាក់កម្រៃនៅទីនោះ ។

- **បុគ្គល** : សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គល ។

- **ប្រតិបត្តិករទេសចរណ៍** : សំដៅដល់បុគ្គលដែលប្រតិបត្តិ ប្រកបអាជីព ឬ ធ្វើអាជីវកម្មលើសេវាកម្មទេសចរណ៍ ។

- **ផលិតផលទេសចរណ៍** : សំដៅដល់ធនធានដែលមានស្រាប់ ឬ ធនធានដែលបង្កើតឡើងជាអាទិ៍ សម្បត្តិវប្បធម៌ ធនធានធម្មជាតិ សម្បទាសេវាកម្ម ទំនិញ សេវាកម្ម

ផលិតផលផ្សេងៗទៀត ដែលអាចបំពេញសេចក្តីត្រូវការ ការចង់បាន និងការផ្ញើសកម្មភាពទេសចរណ៍ ។

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

មាត្រា១.-

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា២.-

អនុក្រឹត្យនេះមានគោលបំណងដូចខាងក្រោម ៖

- រៀបចំបេសកកម្ម និងរចនាសម្ព័ន្ធរបស់ក្រសួងអប់រំ យុវជន និងកីឡា
- រៀបចំមុខងារ និងភារកិច្ចរបស់អង្គភាពនានា នៃក្រសួងអប់រំ យុវជន និងកីឡា
- ធានាគុណភាព និងប្រសិទ្ធភាពនៃលទ្ធផលបំពេញការងារក្នុងវិស័យអប់រំ យុវជន និងកីឡា។

មាត្រា៣.-

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តលើវិស័យអប់រំ យុវជន និងកីឡា នៅគ្រប់អង្គភាពថ្នាក់កណ្តាល ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគ្រឹះស្ថានសិក្សា។

ជំពូកទី ២
បេសកកម្ម និងរចនាសម្ព័ន្ធ

មាត្រា៤.-

ក្រសួងអប់រំ យុវជន និងកីឡា មានបេសកកម្ម ដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡា នៃព្រះរាជាណាចក្រកម្ពុជា ឱ្យឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌របស់កម្ពុជា និងការរីកចម្រើនក្នុងតំបន់ និងសកលលោក។

មាត្រា៥.-

ក្រសួងអប់រំ យុវជន និងកីឡា មានមុខងារ និងភារកិច្ចដូចតទៅ ៖

- កំណត់នយោបាយអប់រំ យុវជន និងកីឡា សំដៅធានាការអភិវឌ្ឍធនធានមនុស្ស ប្រកបដោយចីរភាព
- កសាងនីតិក្រមសម្រាប់អភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡា
- កសាងផែនការអនុវត្ត ពិនិត្យតាមដាន និងវាយតម្លៃនយោបាយអប់រំ យុវជន និងកីឡា ដើម្បីអភិវឌ្ឍធនធានមនុស្ស ព្រមទាំងលើកទិសដៅ និងវិធានការកែលម្អជាបន្តបន្ទាប់តាមគ្រប់មុខជំនាញ
- លើកកម្ពស់គុណភាពវិស័យអប់រំ យុវជន និងកីឡាឱ្យឆ្លើយតបទៅនឹងដំណាក់កាលនីមួយៗនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ចជាតិ និងអន្តរជាតិ ដើម្បីកសាងសមត្ថភាពខាងចំណេះដឹង ចំណេះធ្វើ សីលធម៌ និងចេះរួមរស់ជាមួយគ្នា
- តម្រង់ទិសវិជ្ជាជីវៈ បំណិនជីវិត និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅគ្រប់ភូមិសិក្សា
- ពិនិត្យសំណើ បង្កើត ការបិទ ការរំលាយបញ្ចូលគ្នា ការបង្កើតជំនាញថ្មី ការបំបែក ការប្រែក្លាយ និងទទួលស្គាល់គ្រឹះស្ថានសិក្សា និងថ្នាក់រៀនសាធារណៈ និងឯកជនគ្រប់ប្រភេទ និងគ្រប់កម្រិត

- លើកកម្ពស់ការស្រាវជ្រាវដើម្បីអភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡា
- គ្រប់គ្រង ត្រួតពិនិត្យ វាយតម្លៃដំណើរការសិក្សា ការនិពន្ធ ការផ្សាយ ការនាំចូលសៀវភៅសិក្សា និងឯកសារពាក់ព័ន្ធការបង្រៀន និងរៀន គ្រប់កម្រិតសិក្សា គ្រប់ភូមិសិក្សា និងដាក់ពិន័យ
- ពិនិត្យលើការផ្តល់ បដិសេធ ដកហូតវិញ្ញាបនបត្រ ឬ សញ្ញាបត្រ និងវាយតម្លៃកម្រិតវិញ្ញាបនបត្រ ឬ សញ្ញាបត្រ ចេញដោយគ្រឹះស្ថានសិក្សានានា ទាំងក្នុង និងក្រៅប្រទេស
- ផលិត និងត្រួតពិនិត្យការផ្សព្វផ្សាយព័ត៌មានអប់រំ ការផ្សាយពាណិជ្ជកម្មសិក្សាតាមគ្រប់រូបភាពពាក់ព័ន្ធនឹងវិស័យអប់រំ យុវជន និងកីឡា
- អភិវឌ្ឍការងារយុវជន និងការងារអប់រំកាយ និងកីឡា ដោយកំណត់វិធានគ្រប់គ្រងអប់រំបណ្តុះបណ្តាល និងបំប៉នបច្ចេកទេស
- បង្កើនការយល់ដឹងអំពីវប្បធម៌ជាតិ និងវប្បធម៌អន្តរជាតិ
- គ្រប់គ្រងបុគ្គលិក ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា
- ពិនិត្យ និងផ្តល់យោបល់លើគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋាននានា ដែលពាក់ព័ន្ធនឹងវិស័យអប់រំ យុវជន និងកីឡា
- ធ្វើរបាយការណ៍សកម្មភាពតាមកាលកំណត់ជូនរាជរដ្ឋាភិបាល។

មាត្រា៦.-

ក្រសួងអប់រំ យុវជន និងកីឡា មានរចនាសម្ព័ន្ធដូចខាងក្រោម ៖

I- ថ្នាក់កណ្តាល

ក-អគ្គាធិការដ្ឋាន រួមមានអង្គភាពចំណុះ ៖

- នាយកដ្ឋានធានាគុណភាពអប់រំ
- អធិការដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ។

ខ-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ រួមមានអង្គភាពចំណុះ ៖

- នាយកដ្ឋានរដ្ឋបាល
- នាយកដ្ឋានបុគ្គលិក
- នាយកដ្ឋានហិរញ្ញវត្ថុ
- នាយកដ្ឋានសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ
- នាយកដ្ឋានផែនការ

- នាយកដ្ឋានទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍
- នាយកដ្ឋានព័ត៌មាន និងកិច្ចការអាស៊ាន
- នាយកដ្ឋាននីតិកម្ម
- នាយកដ្ឋានសំណង់ ។

គ-អគ្គនាយកដ្ឋានអប់រំ រួមមានអង្គភាពចំណុះ ÷

- នាយកដ្ឋានអប់រំកុមារតូច
- នាយកដ្ឋានបឋមសិក្សា
- នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ
- នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
- នាយកដ្ឋានសុខភាពសិក្សា
- នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា
- នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ
- នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ
- គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ ។

ឃ-អគ្គនាយកដ្ឋានឧត្តមសិក្សា រួមមានអង្គភាពចំណុះ ÷

- នាយកដ្ឋានឧត្តមសិក្សា
- នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ ។

ង-អគ្គនាយកដ្ឋានយុវជន រួមមានអង្គភាពចំណុះ ÷

- នាយកដ្ឋានយុវជន
- នាយកដ្ឋានគ្រប់គ្រងមជ្ឈមណ្ឌល ។

ច-អគ្គនាយកដ្ឋានកីឡា រួមមានអង្គភាពចំណុះ ÷

- នាយកដ្ឋានអប់រំកាយ និងកីឡា
- នាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស និស្សិត
- មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា
- វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា ។

ឆ-អង្គភាពស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋមន្ត្រី

- នាយកដ្ឋានសវនកម្មផ្ទៃក្នុង
- ខុទ្ទកាល័យ ។

II- អង្គភាពមូលដ្ឋាន

- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ។

III- គ្រឹះស្ថានឧត្តមសិក្សា វិទ្យាស្ថាននានា មានឋានៈស្មើអគ្គនាយកដ្ឋាន ស្ថិតក្រោមអាណាព្យាបាល របស់ក្រសួងអប់រំ យុវជន និងកីឡា :

- សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
- សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- សាកលវិទ្យាល័យជាតិគ្រប់គ្រង
- សាកលវិទ្យាល័យស្វាយរៀង
- សាកលវិទ្យាល័យមានជ័យ
- សាកលវិទ្យាល័យបាត់ដំបង
- វិទ្យាស្ថានជាតិអប់រំ
- សាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ
- វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ។

អង្គការលេខរបស់ក្រសួងអប់រំ យុវជន និងកីឡា ជាឧបសម្ព័ន្ធរបស់អនុក្រឹត្យនេះ ។

ជំពូកទី ៣
អគ្គាធិការដ្ឋាន

មាត្រា៧.-

អគ្គាធិការដ្ឋានមានភារកិច្ចត្រួតពិនិត្យ លើគ្រប់ឋានានុក្រមរដ្ឋបាល និងការងារគ្រប់គ្រងអប់រំ ធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំក្រសួង ពីការប្រព្រឹត្តទៅរបស់អង្គភាពដែលបានធ្វើអធិការកិច្ច និងលើកសំណើវិធានការកែលម្អ ។

អគ្គាធិការដ្ឋានដឹកនាំដោយអគ្គាធិការមួយរូប និងអមដោយអគ្គាធិការរងជាជំនួយការតាមការចាំបាច់ ។

អគ្គាធិការដ្ឋានមានអង្គភាពចំណុះពីរ(០២) គឺ នាយកដ្ឋានធានាគុណភាពអប់រំ និងអធិការដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ដែលមានភារកិច្ចដូចមានចែងក្នុងជំពូកនេះ ។

មាត្រា៨.-

នាយកដ្ឋានធានាគុណភាពអប់រំ ទទួលបន្ទុក ៖

- សិក្សាស្រាវជ្រាវ វិភាគ និងវាយតម្លៃគុណភាព និងប្រសិទ្ធភាពវិស័យអប់រំ

- ពិនិត្យតាមដានការអនុវត្តកម្មវិធីសិក្សា និងការប្រើសម្ភារសិក្សានានា នៅគ្រប់គ្រឹះស្ថានសិក្សារដ្ឋ និងឯកជន
- ពិនិត្យតាមដាន វាយតម្លៃលើការអនុវត្ត ឬ ការបំពេញលក្ខខណ្ឌស្តង់ដារជាតិអប់រំរបស់គ្រឹះស្ថានសិក្សានានា
- ធានាការវាស់ស្ទង់សមត្ថភាពកម្រិតសមមូល
- ពិនិត្យតាមដានលើការអនុវត្តជំនាញយុវជន និងកីឡា
- ពិនិត្យតាមដាន និងលើកសំណើដោះស្រាយករណីមិនប្រក្រតីនានាដែលពាក់ព័ន្ធនឹងបច្ចេកទេសអប់រំ
- ធ្វើរបាយការណ៍សកម្មភាពតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង ។

នាយកដ្ឋានធានាគុណភាពអប់រំ ត្រូវដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានជាជំនួយការតាមការចាំបាច់ ។

មាត្រា៩.-

អធិការដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ទទួលបន្ទុក ៖

- ធ្វើអធិការកិច្ចលើដំណើរការនៃការងារគ្រប់គ្រងបុគ្គលិក រដ្ឋបាល ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ នៅតាមអង្គភាពនិងគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន
- ត្រួតពិនិត្យ និងលើកសំណើដោះស្រាយករណីទាំងឡាយពាក់ព័ន្ធទៅនឹងការងាររដ្ឋបាល និងហិរញ្ញវត្ថុ
- ធ្វើរបាយការណ៍សកម្មភាពតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង ។

អធិការដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ត្រូវដឹកនាំដោយអធិការមួយរូប និងអមដោយអធិការរងជាជំនួយការតាមការចាំបាច់ ។

ជំពូកទី ៤
អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

មាត្រា១០.-

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុមានភារកិច្ចសម្របសម្រួល និងគ្រប់គ្រងកិច្ចការរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិរដ្ឋ ផែនការ ទំនាក់ទំនងវប្បធម៌ក្នុងតំបន់ និងលើសកលលោក ។

អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងជាជំនួយការតាមការចាំបាច់ ។

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មាននាយកដ្ឋានចំណុះចំនួនប្រាំបួន (០៩) ដែលមានភារកិច្ចដូចមានចែងក្នុងជំពូកនេះ ។

មាត្រា១១.-

នាយកដ្ឋានរដ្ឋបាល ទទួលបន្ទុក ៖

- សម្របសម្រួល និងធ្វើទំនាក់ទំនងសកម្មភាពរដ្ឋបាលលើគ្រប់ផ្នែករវាងក្រសួងជាមួយអង្គភាពថ្នាក់កណ្តាល អង្គភាពមូលដ្ឋាន អន្តរក្រសួង និងអាជ្ញាធរដែនដី
- គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលរបស់ក្រសួង និងអន្តរក្រសួង
- រៀបចំសេវាទទួល និងផ្តល់ព័ត៌មាន
- ថែទាំ និងទុកដាក់ឯកសាររដ្ឋបាលគ្រប់ប្រភេទ
- គ្រប់គ្រងទីតាំងក្រសួង ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល សណ្តាប់ធ្នាប់ គ្រប់គ្រងគ្រា និងការងារសង្គម
- គ្រប់គ្រងព័ត៌មានគ្រប់ផ្នែក ធ្វើរបាយការណ៍ និងរៀបចំសន្និបាតការងារអប់រំ យុវជន និងកីឡា
- រៀបចំបែបបទ និងលើកសំណើដើម្បីផ្តល់មេដាយការងារ និងគ្រឿងឥស្សរិយយសផ្សេងៗជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការ
- ធ្វើរបាយការណ៍សកម្មភាពតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង ។

នាយកដ្ឋានរដ្ឋបាល ត្រូវដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

មាត្រា១២.-

នាយកដ្ឋានបុគ្គលិក ទទួលបន្ទុក ៖

- គ្រប់គ្រងក្របខ័ណ្ឌ ការងាររដ្ឋបាល បុគ្គលិកអប់រំ និងភ្នាក់ងាររាជការ របស់ក្រសួងអប់រំ យុវជន និងកីឡា ដោយមានទំនាក់ទំនងជាមួយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- រៀបចំបែបបទជ្រើសរើស តែងតាំង ដំឡើងថ្នាក់ ដំឡើងឋានន្តរសក្តិ ចូលនិវត្តន៍ ផ្លាស់ប្តូរ លើកសរសើរ លើកទឹកចិត្ត ទណ្ឌកម្ម និងលុបឈ្មោះបុគ្គលិកអប់រំ
- រៀបចំសំណុំលិខិត ស្ថិតិបុគ្គលិក និងគ្រប់គ្រងព័ត៌មានបុគ្គលិកតាមប្រព័ន្ធព័ត៌មានវិទ្យា
- ធ្វើកម្មវិធីតំណែងឯកទេស និងធនធានមនុស្ស និងការងារវិភាគមុខងារ
- រៀបចំយុទ្ធសាស្ត្របញ្ច្រាបយេនឌ័រលើការងារគ្រប់គ្រង
- វាយតម្លៃតម្រូវការក្នុងការបណ្តុះបណ្តាលបុគ្គលិកអប់រំ
- រៀបចំបៀវត្ស ប្រាក់កម្រៃ និងរបបឧបត្ថម្ភផ្សេងៗ
- ធ្វើរបាយការណ៍សកម្មភាពតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង ។

នាយកដ្ឋានបុគ្គលិក ត្រូវដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

មាត្រា១៣.-

នាយកដ្ឋានហិរញ្ញវត្ថុ ទទួលបន្ទុក ÷

- រៀបចំផែនការហិរញ្ញវត្ថុរយៈពេលមធ្យមសម្រាប់វិស័យអប់រំ យុវជន និងកីឡា
- ប្រមូលតម្រូវការថវិការបស់អង្គភាពរដ្ឋបាលកណ្តាល និងបូកសរុបរៀបចំគម្រោងចំណូល និងចំណាយថវិកាប្រចាំឆ្នាំ
- រៀបចំសំណើសុំថវិកាពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ចំណាយ និងបើកផ្តល់បែងចែកថវិកាជូនអង្គភាពរដ្ឋបាលកណ្តាល និងរាជធានី ខេត្ត
- ពិនិត្យតាមដានការគ្រប់គ្រង និងប្រើប្រាស់ថវិកាគ្រប់ជំពូកចំណូល ចំណាយរបស់អង្គភាពរដ្ឋបាលកណ្តាល និងរាជធានី ខេត្ត
- រៀបចំលិខិតបទដ្ឋាននានា សម្រាប់ណែនាំដល់ការងារគ្រប់គ្រង និងប្រើប្រាស់ថវិកាគ្រប់ជំពូក
- តាមដានរាល់សកម្មភាពចំណូល ចំណាយ និងរៀបចំរបាយការណ៍បូកសរុប ស្តីពីស្ថានភាពចំណូល ចំណាយថវិកាគ្រប់ប្រភេទរបស់ក្រសួងអប់រំ យុវជន និងកីឡា
- ពិនិត្យតាមដានការគ្រប់គ្រង និងប្រើប្រាស់គណនីគ្រប់ប្រភេទនៅរតនាគារជាតិ និងធនាគារ
- កសាង និងពង្រឹងសមត្ថភាពមន្ត្រីជំនាញ ដែលពាក់ព័ន្ធនឹងការងារគណនេយ្យ ហិរញ្ញវត្ថុ លទ្ធកម្មសាធារណៈ និងប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុ
- រៀបចំប្រព័ន្ធគ្រប់គ្រងប្រព័ន្ធព័ត៌មានហិរញ្ញវត្ថុសម្រាប់អង្គភាពរដ្ឋបាលកណ្តាល និងរាជធានី ខេត្ត
- ធ្វើរបាយការណ៍សកម្មភាពតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង ។

នាយកដ្ឋានហិរញ្ញវត្ថុ ត្រូវដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

មាត្រា១៤.-

នាយកដ្ឋានសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ ទទួលបន្ទុក ÷

- ប្រមូលតម្រូវការ ធ្វើកម្មវិធីចំណាយ គ្រប់គ្រង និងជួសជុលសម្ភារៈ និងបរិក្ខារ
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ

- គ្រប់គ្រងយានដ្ឋាន និងយានយន្តរបស់រដ្ឋ ដែលក្រសួងប្រគល់ជូន
- ទទួល និងបែងចែកសម្ភារបរិក្ខារ ជូនដល់អង្គភាពចំណុះក្រសួង និងរាជធានី ខេត្ត
- គ្រប់គ្រងចំណូលបានមកពីចលនទ្រព្យ និងអចលនទ្រព្យ
- ធ្វើរបាយការណ៍សកម្មភាពតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង ។

នាយកដ្ឋានសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ ត្រូវដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

មាត្រា១៥.-

នាយកដ្ឋានផែនការ ទទួលបន្ទុក ÷

- អភិវឌ្ឍគោលការណ៍ជាមូលដ្ឋានសម្រាប់ដំណើរការរៀបចំយុទ្ធសាស្ត្រ គោលនយោបាយ និងកសាងផែនការអភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡាគ្រប់លំដាប់ថ្នាក់
- រៀបចំ អភិវឌ្ឍ កែលម្អ និងវាយតម្លៃការអនុវត្តផែនការកម្មវិធី និងគម្រោងអភិវឌ្ឍវិស័យអប់រំ ព្រមទាំងរៀបចំរបាយការណ៍វាយតម្លៃការអនុវត្តផែនការអប់រំប្រចាំឆ្នាំនីមួយៗ
- ប្រមូលស្ថិតិអប់រំ ធ្វើបច្ចុប្បន្នភាព និងវិភាគស្ថិតិអប់រំ ដោយប្រើប្រាស់ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ដែលមានស្រាប់ និងធ្វើការបោះពុម្ពផ្សាយជាសាធារណៈ
- សហការរៀបចំប្រព័ន្ធកសាងផែនទីសិក្សាសម្រាប់ថ្នាក់ជាតិ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងផ្សព្វផ្សាយប្រើប្រាស់ជាសាធារណៈ
- ធ្វើអង្កេត និងសិក្សាស្រាវជ្រាវលើប្រព័ន្ធកសាងផែនការ និងរៀបចំគោលនយោបាយអប់រំ
- ធ្វើរបាយការណ៍សកម្មភាពតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង ។

នាយកដ្ឋានផែនការ ត្រូវដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

មាត្រា១៦.-

នាយកដ្ឋានទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍ ទទួលបន្ទុក ÷

- ធ្វើទំនាក់ទំនងជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនិងអង្គការនានាក្នុងតំបន់ និងលើសាកលលោក
- សម្របសម្រួលការងារក្រៅក្រសួង និងការងារអន្តរជាតិ
- រៀបចំឯកសារ និងពិធីការក្នុងកិច្ចសហប្រតិបត្តិការក្នុង និងក្រៅប្រទេស
- ជ្រើសរើស និងគ្រប់គ្រងសិស្ស និស្សិតអាហារូបករណ៍ និងកម្មសិក្សាការីខ្មែរនៅបរទេស និងគ្រប់គ្រងនិស្សិតអាហារូបករណ៍បរទេសនៅកម្ពុជា
- រៀបចំការប្រឡងជ្រើសរើសសិស្ស និស្សិតអាហារូបករណ៍ទៅសិក្សានៅបរទេស

- ធ្វើស្ថិតិ សិស្ស និស្សិតអាហារូបករណ៍បញ្ចប់ការសិក្សាមកពីបរទេស ដើម្បីបញ្ជូនទៅស្ថាប័នពាក់ពន្ធ័
- ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយប្រទេសផ្តល់ជំនួយអង្គការអន្តរជាតិនានាក្នុងតំបន់ និងលើសកលលោក
- ធ្វើរបាយការណ៍សកម្មភាពតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង ។

នាយកដ្ឋានទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍ ត្រូវដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

មាត្រា១៧.-

នាយកដ្ឋានព័ត៌មាន និងកិច្ចការអាស៊ាន ទទួលបន្ទុក ÷

- ប្រមូលផ្តុំព័ត៌មានសាធារណៈ និងផ្សព្វផ្សាយព័ត៌មានអប់រំ យុវជន និងកីឡា
- គ្រប់គ្រងការងារព័ត៌មានវិទ្យា និងសារគមនាគមន៍ក្នុងវិស័យអប់រំ យុវជន និងកីឡា
- ត្រួតពិនិត្យ និងតាមដានដំណើរការបណ្តុះបណ្តាលវិស័យព័ត៌មានវិទ្យា
- គ្រប់គ្រងការអប់រំមិនផ្លូវការ
- ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍
- ទំនាក់ទំនងការងារអប់រំ យុវជន និងកីឡា ជាមួយក្រសួង ស្ថាប័នជាតិ និងបណ្តាប្រទេស សមាជិកអាស៊ាន
- ធ្វើរបាយការណ៍សកម្មភាពតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង ។

នាយកដ្ឋានព័ត៌មាន និងកិច្ចការអាស៊ាន ត្រូវដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

មាត្រា១៨.-

នាយកដ្ឋាននីតិកម្ម ទទួលបន្ទុក ÷

- ជាសេនាធិការរបស់ក្រសួងលើការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- រៀបចំតាក់តែងច្បាប់ លិខិតបទដ្ឋាន និងគោលនយោបាយផ្សេងៗ ដោយសហការជាមួយអង្គភាពពាក់ព័ន្ធ
- ពិនិត្យ ផ្តល់យោបល់ កែសម្រួលលើទម្រង់ និងខ្លឹមសារគតិយុត្តនៃសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋាន និងគោលនយោបាយផ្សេងៗ ដែលរៀបចំដោយអង្គភាពជំនាញ និងស្ថាប័នពាក់ព័ន្ធ
- រៀបចំ ចងក្រង និងគ្រប់គ្រងទិន្នន័យគតិយុត្ត ក្នុងវិស័យអប់រំ យុវជន និងកីឡា

- បណ្តុះបណ្តាល និងផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋាន និងគោលនយោបាយជាធរមាន
- ពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តច្បាប់ និងលិខិតបទដ្ឋាន
- គ្រប់គ្រង និងតាមដានការងារវិវាទរបស់បុគ្គលិកអប់រំ និងលើកសំណើអំពីវិធានគតិយុត្ត ដែលពាក់ព័ន្ធជូនថ្នាក់ដឹកនាំសម្រេច
- ធ្វើរបាយការណ៍សកម្មភាពតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង ។

នាយកដ្ឋាននីតិកម្ម ត្រូវដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

មាត្រា១៩.-

នាយកដ្ឋានសំណង់ ទទួលបន្ទុក ៖

- រៀបចំបទដ្ឋានស្តង់ដារនានា ពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត
- ប្រមូលផ្តុំទិន្នន័យពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត
- សិក្សាអំពីតម្រូវការអគារសិក្សា ដោយផ្អែកទៅលើទិន្នន័យរបស់សិស្សានុសិស្ស
- រៀបចំគំនូសប្លង់ និងសិក្សាពីទំហំ ខ្នាត ផែនការលម្អិតបច្ចេកទេស ពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត
- ត្រួតពិនិត្យបច្ចេកទេសប្រតិបត្តិលទ្ធកម្មសាធារណៈលើគម្រោងសាងសង់ថ្មី ការងារជួសជុល និងត្រួតពិនិត្យការអនុវត្ត ការជួសជុល និងការសាងសង់អគារផ្សេងៗ
- សហប្រតិបត្តិការជាមួយបណ្តាអង្គការ ឬ សប្បុរសជននានា លើផ្នែកបច្ចេកទេស និងបទដ្ឋានផ្សេងៗ
- ធ្វើរបាយការណ៍សកម្មភាពតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង ។

នាយកដ្ឋានសំណង់ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

ជំពូកទី ៥
អគ្គនាយកដ្ឋានអប់រំ

មាត្រា២០.-

អគ្គនាយកដ្ឋានអប់រំមានភារកិច្ច សម្របសម្រួល គ្រប់គ្រង និងអភិវឌ្ឍការអប់រំកុមារតូច បឋមសិក្សា មធ្យមសិក្សាចំណេះទូទៅ ការអប់រំក្រៅប្រព័ន្ធ កម្មវិធីសិក្សា និងសៀវភៅសិក្សា សុខភាពសិក្សា ការបណ្តុះបណ្តាល និងវិក្រឹតការ តម្រង់ទិសវិជ្ជាជីវៈ បំណិនជីវិត និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

អគ្គនាយកដ្ឋានអប់រំដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងជាជំនួយការតាមការចាំបាច់ ។

អគ្គនាយកដ្ឋានអប់រំ មាននាយកដ្ឋានចំណុះចំនួនប្រាំបី (០៨) និងគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយមួយ (០១)ដែលអង្គភាពនីមួយៗ មានភារកិច្ចដូចមានចែងក្នុងជំពូកនេះ ។

មាត្រា២១.-

នាយកដ្ឋានអប់រំកុមារតូច ទទួលបន្ទុក ÷

- អប់រំកុមារតូច ពី ០ ឆ្នាំ ទៅ ៧០ ខែ
- កសាងផែនការអប់រំ និងអភិវឌ្ឍកុមារតូចរយៈពេលវែង មធ្យម ខ្លី ដោយសហការជាមួយក្រសួងស្ថាប័នពាក់ពន្ធ័ អង្គការជាតិ អន្តរជាតិ និងសហគមន៍
- កសាងគោលនយោបាយ គោលការណ៍ លិខិតបទដ្ឋានផ្សេងៗ ដើម្បីគ្រប់គ្រង និងអភិវឌ្ឍការងារអប់រំកុមារតូច
- គ្រប់គ្រង ត្រួតពិនិត្យតាមដានថ្នាក់ និងសាលាមត្តេយ្យសិក្សារដ្ឋ និងឯកជន
- ជំរុញការអភិវឌ្ឍមត្តេយ្យសហគមន៍ ទារកដ្ឋាន និងមត្តេយ្យសិក្សាខ្នងផ្ទះ
- ពិនិត្យតាមដាន និងកែលម្អការអនុវត្តកម្មវិធីសិក្សា និងបច្ចេកទេសគរុកោសល្យ
- សិក្សាលើសំណើបង្កើត បើក ទទួលស្គាល់ បិទសាលាមត្តេយ្យសិក្សារដ្ឋ និងឯកជន និងទារកដ្ឋាន
- ធ្វើរបាយការណ៍សកម្មភាពតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង ។

នាយកដ្ឋានអប់រំកុមារតូច ត្រូវដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

មាត្រា២២.-

នាយកដ្ឋានបឋមសិក្សា ទទួលបន្ទុក ÷

- ធានាការបណ្តុះបណ្តាលបុគ្គលិកលក្ខណៈពេញលេញលើផ្នែករាងកាយ បញ្ញា សីលធម៌ តម្លៃ និងបំណិនមូលដ្ឋានដំបូងចាំបាច់
- អភិវឌ្ឍសាលារៀន ថ្នាក់រៀន ការងារគ្រប់គ្រង និងបច្ចេកទេសសាលាបឋមសិក្សាសាធារណៈ និងឯកជនឱ្យស្របតាមកម្មវិធីសិក្សាគោល
- ពិនិត្យតាមដានដំណើរការសិក្សាអប់រំ និងបំផុសលើកទឹកចិត្ត ការអភិវឌ្ឍនៅគ្រប់សាលារៀនបឋមសិក្សាសាធារណៈ និងឯកជន
- សិក្សាលើសំណើសុំបង្កើត បើក ទទួលស្គាល់ បិទសាលារៀនបឋមសិក្សាសាធារណៈ និងឯកជន
- កសាងគោលនយោបាយ គោលការណ៍ និងលិខិតបទដ្ឋានផ្សេងៗដើម្បីគ្រប់គ្រង និងអភិវឌ្ឍការងារអប់រំបឋមសិក្សា
- អភិវឌ្ឍការអប់រំបញ្ចូលគ្នា ដើម្បីធានាឱ្យកុមារទទួលបានការអប់រំប្រកបដោយសមធម៌
- ពិនិត្យតាមដានការរីកចម្រើន និងលើកទិសដៅអភិវឌ្ឍបន្ត

- ធ្វើរបាយការណ៍សកម្មភាពតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង ។

នាយកដ្ឋានបឋមសិក្សា ត្រូវដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

មាត្រា២៣.-

នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ទទួលបន្ទុក ÷

- ធានាការបណ្តុះបណ្តាលបុគ្គលិកលក្ខណៈពេញលេញដោយពង្រីកវិសាលភាពចំណេះដឹងនៅបឋមសិក្សា និងមានលក្ខណៈសម្បត្តិបន្តការសិក្សា
- អភិវឌ្ឍ និងគ្រប់គ្រងបច្ចេកទេសសាលារៀនមធ្យមសិក្សាចំណេះទូទៅសាធារណៈ និងឯកជន
- គ្រប់គ្រងការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សជាប់ជាប្រចាំ
- កំណត់និយាមគរុកោសល្យ និងមូលដ្ឋានសម្ភារៈសម្រាប់អភិវឌ្ឍសាលារៀនមធ្យមសិក្សាចំណេះទូទៅសាធារណៈ និងឯកជន
- សិក្សាលើសំណើបង្កើត បើក ទទួលស្គាល់ បិទសាលារៀនមធ្យមសិក្សាចំណេះទូទៅសាធារណៈ និងឯកជន
- ធ្វើរបាយការណ៍សកម្មភាពតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង ។

នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ត្រូវដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

មាត្រា២៤.-

នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ ទទួលបន្ទុក ÷

- គ្រប់គ្រងការងារអក្ខរកម្ម ក្រោយអក្ខរកម្ម និងកម្មវិធីសមមូល ដោយផ្តល់ចំណេះដឹងទូទៅ ជំនាញវិជ្ជាជីវៈ ជំនាញមុខរបរ
- កសាងកម្មវិធីសិក្សា ឯកសាររៀន និងបង្រៀនសម្រាប់កម្មវិធីអក្ខរកម្ម ក្រោយអក្ខរកម្ម និងកម្មវិធីសមមូលគ្រប់ភូមិសិក្សា
- បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងមុខរបរដល់ប្រជាពលរដ្ឋគ្រប់ភេទ គ្រប់វ័យ តាមរយៈមជ្ឈមណ្ឌលសិក្សាសហគមន៍
- ពិនិត្យតាមដានដំណើរការសិក្សាក្នុងសាលារៀន និងថ្នាក់រៀន អប់រំក្រៅប្រព័ន្ធគ្រប់ប្រភេទ
- រៀបចំប្រព័ន្ធទិន្នន័យអប់រំក្រៅប្រព័ន្ធ
- ផ្សព្វផ្សាយព័ត៌មាន និងសម្របសម្រួលសកម្មភាពអប់រំក្រៅប្រព័ន្ធជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការនានា

- ធ្វើរបាយការណ៍សកម្មភាពតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង ។

នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ ត្រូវដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

មាត្រា២៥.-

នាយកដ្ឋានសុខភាពសិក្សា ទទួលបន្ទុក ៖

- គ្រប់គ្រង និងអភិវឌ្ឍកម្មវិធីអប់រំសុខភាព និងអនាម័យតាមគ្រឹះស្ថានសិក្សា
- គ្រប់គ្រងបន្ទប់សង្គ្រោះបឋមនៅតាមគ្រឹះស្ថានសិក្សា
- ពិនិត្យសុខភាពបុគ្គលិកអប់រំ និងអ្នកសិក្សា ដោយសហការជាមួយក្រសួងសុខាភិបាល
- ពិនិត្យតាមដាន ស្រាវជ្រាវ និងលើកវិធានការទប់ស្កាត់ជំងឺរាតត្បាតនានា តាមគ្រឹះស្ថានសិក្សា
- ធ្វើរបាយការណ៍សកម្មភាពតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង ។

នាយកដ្ឋានសុខភាពសិក្សា ត្រូវដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

មាត្រា២៦.-

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ទទួលបន្ទុក ៖

- អភិវឌ្ឍ និងផ្សព្វផ្សាយកម្មវិធីសិក្សាជាតិ និងកម្មវិធីបំណិនជីវិតឱ្យបានទូលំទូលាយ
- អភិវឌ្ឍឯកសារគរុកោសល្យ បច្ចេកទេសបណ្ណាល័យ និងសម្ភារឧបទេស
- ពិនិត្យតាមដាន ការនិពន្ធ ការផ្សព្វផ្សាយ និងការនាំចូលសម្ភារសិក្សា សៀវភៅសិក្សា និង ឯកសារពាក់ព័ន្ធការបង្រៀន និងរៀន
- ពិនិត្យតាមដានការអនុវត្តកម្មវិធីសិក្សាគោល ការគ្រប់គ្រងបណ្ណាល័យ និងកម្មវិធីបំណិនជីវិត
- ណែនាំអំពីគោលការណ៍អភិវឌ្ឍ និងផ្គត់ផ្គង់សៀវភៅសិក្សា
- សិក្សាស្រាវជ្រាវខ្លឹមសារកម្មវិធីសិក្សាជាតិ និងអន្តរជាតិ
- ធ្វើរបាយការណ៍សកម្មភាពតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង ។

នាយកដ្ឋានកម្មវិធីសិក្សា និងស្តង់ដារ ត្រូវដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

មាត្រា២៧.-

នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ទទួលបន្ទុក ៖

- កសាងផែនការបណ្តុះបណ្តាលក្របខ័ណ្ឌបុគ្គលិកអប់រំ ដោយសហការជាមួយអង្គភាពពាក់ព័ន្ធ

- រៀបចំកម្មវិធីបណ្តុះបណ្តាល និងវិក្រឹតការ
- គ្រប់គ្រងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ សាលាគរុកោសល្យ និងវិក្រឹតការរាជធានី ខេត្ត និងសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម
- ពិនិត្យតាមដានសមត្ថភាពវិជ្ជាជីវៈរបស់បុគ្គលិកអប់រំ
- ធ្វើរបាយការណ៍សកម្មភាពតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង ។

នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ត្រូវដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

មាត្រា២៨.-

នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ ទទួលបន្ទុក ÷

- កសាងគោលនយោបាយ សម្រាប់អភិវឌ្ឍការងារបណ្តុះបណ្តាលអប់រំបច្ចេកទេសវិជ្ជាជីវៈ
- កសាងផែនការ សកម្មភាពបណ្តុះបណ្តាល និងតម្រូវការមុខជំនាញ សំដៅធានាដល់ប្រសិទ្ធភាព នៃការផ្តល់សេវាអប់រំ ដល់អ្នកសិក្សានៅតាមសហគមន៍
- ពិនិត្យតាមដានដំណើរការ តម្រង់ទិសវិជ្ជាជីវៈ បំណិនជីវិត និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅតាមគ្រឹះស្ថានសិក្សា
- ធ្វើរបាយការណ៍សកម្មភាពតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង ។

នាយកដ្ឋានបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

មាត្រា២៩.-

គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ ទទួលបន្ទុក ÷

- រៀបរៀង និងបោះពុម្ពកម្មវិធីសិក្សា សៀវភៅសិក្សា ឯកសារគរុកោសល្យ ផលិតសម្ភារឧបទេស ឯកសារផ្សេងៗរបស់ក្រសួង និងចែកផ្សាយឱ្យប្រើប្រាស់សម្រាប់ការអប់រំចំណេះទូទៅ និងអប់រំក្រៅប្រព័ន្ធ
- ត្រួតពិនិត្យការប្រើប្រាស់សៀវភៅសិក្សា ឯកសារគរុកោសល្យ សម្ភារឧបទេសឱ្យសមស្របតាមគោលការណ៍របស់ក្រសួង
- អនុវត្តក្នុងតួនាទីជាសហគ្រាសសាធារណៈតាមស្មារតីច្បាប់ អនុក្រឹត្យ លក្ខន្តិកៈទូទៅនៃសហគ្រាស ។

ជំពូកទី ៦

អគ្គនាយកដ្ឋានឧត្តមសិក្សា

មាត្រា៣០.-

អគ្គនាយកដ្ឋានឧត្តមសិក្សាមានភារកិច្ចគ្រប់គ្រង សម្របសម្រួល និងអភិវឌ្ឍការងារបណ្តុះបណ្តាល កម្រិតក្រោយមធ្យមសិក្សា និងការងារស្រាវជ្រាវវិទ្យាសាស្ត្រ និងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ ។

អគ្គនាយកដ្ឋានឧត្តមសិក្សា ដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករង ជាជំនួយការតាមការចាំបាច់ ។

អគ្គនាយកដ្ឋានឧត្តមសិក្សា មាននាយកដ្ឋានចំណុះចំនួនពីរ (០២) ដែលមានភារកិច្ចដូចមានចែងក្នុងជំពូកនេះ ។

មាត្រា៣១.-

នាយកដ្ឋានឧត្តមសិក្សា ទទួលបន្ទុក ÷

- ធានាការបណ្តុះបណ្តាលបុគ្គលិកលក្ខណៈពេញលេញ និងជំរុញការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ បច្ចេកទេស វប្បធម៌ និងសង្គម
- កសាងគោលនយោបាយ និងផែនការអភិវឌ្ឍវិស័យឧត្តមសិក្សា
- គ្រប់គ្រង និងសម្របសម្រួលការងារសិក្សា នៃគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជន
- គ្រប់គ្រងទិន្នន័យ និងប្រព័ន្ធព័ត៌មានឧត្តមសិក្សា និងត្រួតពិនិត្យការផ្សព្វផ្សាយពាណិជ្ជកម្មសិក្សា
- ជ្រើសរើសនិស្សិតឱ្យចូលរៀនថ្នាក់ឆ្នាំសិក្សាមូលដ្ឋាននៃឧត្តមសិក្សា
- ជ្រើសរើស និងគ្រប់គ្រងនិស្សិតនៅក្នុងប្រទេស
- សិក្សាលើសំណើបង្កើត បើក បិទ រំលាយបញ្ចូលគ្នា បង្កើតជំនាញថ្មី បំបែក ប្រែក្លាយ និងទទួលស្គាល់គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជន
- ធ្វើរបាយការណ៍សកម្មភាពតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង ។

នាយកដ្ឋានឧត្តមសិក្សា ត្រូវដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

មាត្រា៣២.-

នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ ទទួលបន្ទុក ÷

- លើកកម្ពស់ និងគាំទ្រការសិក្សាស្រាវជ្រាវ ការអភិវឌ្ឍ ការច្នៃប្រឌិត និងការផលិតដែលមានលក្ខណៈវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- កសាងគោលនយោបាយ និងផែនការសម្រាប់អភិវឌ្ឍការងារស្រាវជ្រាវវិទ្យាសាស្ត្រ និងបណ្តុះបណ្តាល
- ពិនិត្យតាមដាន និងវាយតម្លៃលទ្ធផល នៃការស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកទេស ។
- ធ្វើរបាយការណ៍សកម្មភាពតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង ។

នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ ត្រូវដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

ជំពូកទី ៧
អគ្គនាយកដ្ឋានយុវជន

មាត្រា៣៣.-

អគ្គនាយកដ្ឋានយុវជនមានភារកិច្ចសម្របសម្រួល និងគ្រប់គ្រងកិច្ចការយុវជន និងកុមារ នៅក្នុងក្របខ័ណ្ឌក្រសួង និងសង្គមជាតិ ។

អគ្គនាយកដ្ឋានយុវជន ដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងជាជំនួយការតាមការចាំបាច់ ។

អគ្គនាយកដ្ឋានយុវជន មាននាយកដ្ឋានចំណុះចំនួនពីរ (០២)ដែលមានភារកិច្ចដូចមានចែងក្នុងជំពូកនេះ ។

មាត្រា៣៤.-

នាយកដ្ឋានយុវជន ទទួលបន្ទុក ៖

- កសាងគោលនយោបាយ ផែនការ និងលិខិតបទដ្ឋានដើម្បីអភិវឌ្ឍការងារយុវជន និងកុមារ
- សហការជាមួយអង្គភាព និងដៃគូអភិវឌ្ឍន៍លើការងារយុវជន និងកុមារ
- បណ្តុះបណ្តាលបញ្ញា ស្មារតី និងបំផុសចិត្តគំនិតយុវជន និងកុមារឱ្យមានសីលធម៌រស់នៅថ្លៃថ្នូរ គិតគូរពីបញ្ហាបុគ្គលខ្លួនឯង គ្រួសារ សង្គមប្រទេសជាតិ
- លើកកម្ពស់ចលនាប្រឡងប្រណាំង ៣ល្អ កូនល្អ សិស្សល្អ មិត្តល្អ របស់កុមារ និងយុវជន
- ធ្វើរបាយការណ៍សកម្មភាពតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង ។

នាយកដ្ឋានយុវជន ត្រូវដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

មាត្រា៣៥.-

នាយកដ្ឋានគ្រប់គ្រងមជ្ឈមណ្ឌល ទទួលបន្ទុក ៖

- ណែនាំការបង្កើត និងការរៀបចំដំណើរការអភិវឌ្ឍ មជ្ឈមណ្ឌលយុវជន រាជធានី ខេត្ត
- សហការជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីណែនាំ និងអប់រំយុវជនក្រៅសាលាឱ្យទទួលបានការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ សម្រាប់ជីវភាពរស់នៅ និងបំពេញការងាររបស់ខ្លួន
- លើកកម្ពស់ការស្ម័គ្រចិត្តរបស់យុវជន ក្នុងការចុះជួយការងារនៅតាមមូលដ្ឋាននានា
- សិក្សាស្រាវជ្រាវ និងរៀបចំផែនការសម្រាប់ដំណើរការមជ្ឈមណ្ឌលជាតិរាជធានី ខេត្ត
- ធ្វើរបាយការណ៍សកម្មភាពតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង ។

នាយកដ្ឋានគ្រប់គ្រងមជ្ឈមណ្ឌល ត្រូវដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

ជំពូកទី ៨
អគ្គនាយកដ្ឋានកីឡា

មាត្រា៣៦.-

អគ្គនាយកដ្ឋានកីឡាមានភារកិច្ចគ្រប់គ្រង និងអភិវឌ្ឍការងារអប់រំកាយ និងកីឡានៅក្នុងក្រសួង និងសង្គមជាតិ ។

អគ្គនាយកដ្ឋានកីឡា ដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងជាជំនួយការតាមការចាំបាច់ ។

អគ្គនាយកដ្ឋានកីឡា មានអង្គភាពចំណុះចំនួនបួន(០៤) ដែលមានភារកិច្ចដូចមានចែងក្នុងជំពូកនេះ ។

មាត្រា៣៧.-

នាយកដ្ឋានអប់រំកាយ និងកីឡា ទទួលបន្ទុក ÷

- អភិវឌ្ឍសហព័ន្ធកីឡាគ្រប់ប្រភេទ
- សិក្សាស្រាវជ្រាវការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា
- សហការជាមួយសហព័ន្ធកីឡាជាតិ គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា និងអង្គភាពពាក់ព័ន្ធ លើបច្ចេកទេសកីឡាសម្រាប់ការប្រកួតក្នុង និងក្រៅប្រទេស
- រៀបចំការប្រកួតកីឡាសហព័ន្ធជាតិដែលមាន ដើម្បីជ្រើសរើសជើងឯកជាផ្លូវការទូទាំងប្រទេស
- សហការជាមួយអង្គភាពពាក់ព័ន្ធលើការស្រាវជ្រាវ គ្រប់គ្រង និងផ្សព្វផ្សាយស្ថិតិប្រព័ន្ធទិន្នន័យព័ត៌មានអំពីវិស័យអប់រំកាយ និងកីឡា
- បំផុស ស្តារ និងអភិវឌ្ឍកីឡាប្រពៃណីជាតិ
- បំផុសសកម្មភាពហាត់ប្រាណ ដើម្បីសុខភាពរបស់មហាជនគ្រប់ស្រទាប់
- គ្រប់គ្រង និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធកីឡាមហាជនទូទាំងប្រទេស
- ធ្វើរបាយការណ៍សកម្មភាពតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង ។

នាយកដ្ឋានអប់រំ និងកីឡា ត្រូវដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

មាត្រា៣៨.-

នាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស និស្សិត ទទួលបន្ទុក ÷

- គ្រប់គ្រងការងារអប់រំកាយ និងកីឡាសិស្ស និស្សិតគ្រប់គ្រឹះស្ថានសិក្សា
- បំផុស និងអភិវឌ្ឍសកម្មភាពអប់រំកាយ និងកីឡាតាមគ្រឹះស្ថានសិក្សាក្នុង និងក្រៅម៉ោងសិក្សា

- ជំរុញសកម្មភាពសហព័ន្ធកីឡាសិស្ស និស្សិត ដើម្បីចូលរួមប្រកួតលើឆាកអន្តរជាតិ
- រៀបចំកម្មវិធីសិក្សាមុខវិជ្ជាអប់រំកាយ និងកីឡា
- រៀបចំប្រកួតកីឡាសិស្ស និស្សិត និងពិនិត្យតាមដានលើមុខវិជ្ជាអប់រំកាយ និងកីឡា
- ធ្វើរបាយការណ៍សកម្មភាពតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង ។

នាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស និស្សិត ត្រូវដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

មាត្រា៣៩.-

មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា ទទួលបន្ទុក ÷

- អភិវឌ្ឍវិស័យកីឡាកម្រិតខ្ពស់
- ប្រមូលផ្តុំគ្រូបង្វឹក អនុរក្ស កីឡាករ កីឡាការិនីជម្រើសជាតិគ្រប់ប្រភេទកីឡា មកធ្វើការបំប៉ន ហាត់ហ្វឹកហ្វឺន
- សហការជាមួយគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា និងអង្គភាពពាក់ព័ន្ធ ដើម្បីបញ្ជូនកីឡាករ កីឡាការិនី និងគ្រូជម្រើសជាតិទៅចូលរួមប្រកួតក្រៅប្រទេស
- បង្កើត និងគ្រប់គ្រងមជ្ឈមណ្ឌលហ្វឹកហ្វឺនកីឡាតាមភូមិភាគ
- សិក្សាស្រាវជ្រាវ ពិនិត្យតាមដានលទ្ធផលបច្ចេកទេសកីឡាកម្រិតខ្ពស់
- ធ្វើរបាយការណ៍សកម្មភាពតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង ។

មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា មានឋានៈស្មើនាយកដ្ឋាន ត្រូវដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

មាត្រា៤០.-

វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា ទទួលបន្ទុក ÷

- បណ្តុះបណ្តាលធនធានមនុស្សលើផ្នែកអប់រំកាយ និងកីឡា
- បណ្តុះបណ្តាលគ្រូអប់រំកាយ និងកីឡា
- ធ្វើក្រឹតការ និងពិនិត្យតាមដាន វាយតម្លៃគ្រូអប់រំកាយ និងកីឡា
- សិក្សាស្រាវជ្រាវឯកសារពាក់ព័ន្ធកីឡាជាតិ និងអន្តរជាតិ
- សម្របសម្រួល និងសហការជាមួយនាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស និស្សិត ពាក់ព័ន្ធការងារអប់រំកាយ និងកីឡា
- អភិវឌ្ឍវិស័យកីឡាដោយសហការជាមួយសហព័ន្ធកីឡាជាតិ និងគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា និងអង្គភាពពាក់ព័ន្ធ
- ធ្វើរបាយការណ៍សកម្មភាពតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង ។

វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា មានឋានៈស្មើនាយកដ្ឋាន ត្រូវដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

ជំពូកទី ៩
នាយកដ្ឋានសវនកម្មផ្ទៃក្នុង

មាត្រា៤១.-

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ទទួលបន្ទុក ៖

- កំណត់នូវភាពសមស្រប គ្រប់គ្រាន់ និងការផ្តល់លទ្ធផលល្អលើប្រពន្ធ័ត្រួតពិនិត្យផ្ទៃក្នុងផ្នែកគណនេយ្យ រដ្ឋបាល និងកិច្ចប្រតិបត្តិការរបស់អង្គភាព
- ពិនិត្យឡើងវិញនូវភាពដែលអាចជឿទុកចិត្តបាន ភាពទាន់ពេលវេលា ភាពច្បាស់លាស់នូវព័ត៌មានហិរញ្ញវត្ថុ និងកិច្ចប្រតិបត្តិការ ព្រមទាំងវិធីសាស្ត្រដែលប្រើប្រាស់អនុលោមតាមគោលការណ៍ ផែនការ នីតិវិធីច្បាប់
- ពិនិត្យឡើងវិញលើការគ្រប់គ្រង ការថែទាំ ការពារទ្រព្យសម្បត្តិ និងធ្វើការផ្ទៀងផ្ទាត់ទ្រព្យសម្បត្តិឱ្យបានត្រឹមត្រូវ
- វាយតម្លៃភាពសន្សំសំចៃ ប្រសិទ្ធភាព និងភាពផ្តល់ផលវិជ្ជមានពីការប្រើប្រាស់ធនធាន ផ្តល់អនុសាសន៍លើចំណុចខ្វះខាត ដើម្បីដោះស្រាយបញ្ហាឱ្យបានសមស្រប
- ពិនិត្យឡើងវិញលើប្រតិបត្តិការកម្មវិធី និងគម្រោងចំណាយអភិវឌ្ឍមូលធន ដើម្បីធានាថាលទ្ធផលស្របតាមកម្មវត្ថុ និងទិសដៅដែលបានកំណត់
- ធ្វើសវនកម្មលើប្រព័ន្ធកុំព្យូទ័រតាមការិយបរិច្ឆេទ និងធ្វើការវាយតម្លៃលើប្រព័ន្ធដំណើរការទិន្នន័យសំខាន់ៗក្រោយពេលដំឡើងរួចដើម្បីកំណត់ប្រព័ន្ធទាំងនោះ ឆ្លើយតបតាមគោលបំណង និងគោលដៅដែលបានគ្រោងទុក
- សម្របសម្រួលការងារសវនកម្មផ្ទៃក្នុងជាមួយអាជ្ញាធរសវនកម្មជាតិ ដើម្បីធានាទំហំការងារឱ្យបានគ្រប់គ្រាន់ និងកាត់បន្ថយការងារស្ទួនគ្នា
- វាយតម្លៃផែនការ ឬ សកម្មភាពកែតម្រូវលើចំណុចរកឃើញរបស់សវនកម្មផ្ទៃក្នុង
- ធ្វើរបាយការណ៍សកម្មភាពតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួង ។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ត្រូវដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

ជំពូកទី ១០
ខុទ្ទកាល័យ

មាត្រា៤២.-

ខុទ្ទកាល័យរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មទាំងឡាយ ដែលកំណត់តាមបទប្បញ្ញត្តិ នៃអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ដូចមានយោងក្នុងមូលបទខាងលើ ។

ជំពូកទី ១១
អង្គភាពមូលដ្ឋាន

មាត្រា៤៣.-

នៅតាមរាជធានី ខេត្តនីមួយៗមានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងគ្រឹះស្ថានសិក្សាទទួលបន្ទុកអនុវត្តតួនាទី និងមុខងាររបស់ក្រសួង។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពមូលដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួង។

ជំពូកទី ១២
គ្រឹះស្ថានសិក្សាស្ថិតក្រោមអាណាព្យាបាលរបស់ក្រសួងអប់រំ យុវជន និងកីឡា

មាត្រា៤៤.-

គ្រឹះស្ថានឧត្តមសិក្សាដែលមានចែងក្នុងមាត្រា៦ នៃអនុក្រឹត្យនេះ មានមុខងាររៀបចំបណ្តុះបណ្តាលនិស្សិតកម្រិតឧត្តមសិក្សា។

ការរៀបចំ និងការប្រព្រឹត្តទៅ របស់គ្រឹះស្ថានឧត្តមសិក្សាទាំងនេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡា លើកលែងតែគ្រឹះស្ថានសាធារណៈឧបនិស្ស័យរដ្ឋបាល ដែលត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។

ជំពូកទី ១៣
អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

មាត្រា៤៥.-

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមលក្ខខណ្ឌនៃបទបញ្ជាកំណត់ក្នុងអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកាក្នុងបណ្តាក្រសួង។

ជំពូកទី ១៤
អវសានប្បញ្ញត្តិ

មាត្រា៤៦.-

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ថ្នាក់រដ្ឋបាលកណ្តាល ចាប់ពីក្រោមថ្នាក់នាយកដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា៤៧.-

អនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា និងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៤៨.-

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

ដើម្បីសូមចុះហត្ថលេខា

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

អ៊ឹម សេធី

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម និងលោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ០១ នៃអនុក្រឹត្យលេខ៥១៤.អនក្រ.បក
ចុះថ្ងៃទី.២៨.ខែ.មិថុនាឆ្នាំ២០០៩

គ្រឹះស្ថានសិក្សា និងមជ្ឈមណ្ឌលផ្សេងៗទៀត
ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា

១. សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម
២. មជ្ឈមណ្ឌលគរុកោសល្យភូមិភាគរាជធានី ខេត្ត
៣. សាលាគរុកោសល្យរាជធានី ខេត្ត

ឧបសម្ព័ន្ធ០២ នៃអនុក្រឹត្យលេខ ៨៤ អនក្រ.បក
ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០០៩

អង្គការលេខរបស់ក្រសួងអប់រំ យុវជន និងកីឡា



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៧៤ .អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ បំពាក់ជូនមន្ត្រីរាជការ និង បុគ្គលិកសិក្សា ខេត្តព្រៃវែង ចំនួន ៧០៣ រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចជូនជាតិកន្លងមក ដូចមានរាយនាមខាងក្រោម :-

ក.មេដាយមាសការងារ

១	លោក	ទុង	ធុនហេង	អនុប្រធាន	មន្ទីរអប់រំ យុវជន និង កីឡាខេត្ត	កំពង់លាវ
២	លោក	អំ	សំអេង	អនុប្រធាន	មន្ទីរអប់រំ យុវជន និង កីឡាខេត្ត	កំពងលាវ
៣	លោក	វ៉ែន	ប្រណិ	អនុប្រធាន	មន្ទីរអប់រំ យុវជន និង កីឡាខេត្ត	កំពងលាវ
៤	លោកស្រី	បួយ	សុខុន	អនុប្រធាន	ការិយាល័យ មធ្យមសិក្សា	កំពងលាវ
៥	លោកស្រី	ឈន	ចន្ថាលា	អនុប្រធាន	ការិយាល័យ ប្រឡង	កំពងលាវ
៦	លោកស្រី	ម៉ី	ស៊ីអេង	អនុប្រធាន	ការិយាល័យ រដ្ឋបាល	កំពងលាវ
៧	លោក	យឹម	ត្រី	អនុប្រធាន	ការិយាល័យ បឋមសិក្សា	កំពងលាវ
៨	លោក	ម៉ុក	សុបិន	អនុប្រធាន	ការិយាល័យ គណនេយ្យ	កំពងលាវ
៩	លោក	ធីវ	ឌឿន	អនុប្រធាន	ការិយាល័យ គណនេយ្យ	កំពងលាវ

១០	លោក	សេង	សុខា	អនុប្រធាន	ការិយាល័យ ផែនការ	កំពង់លាវ
១១	លោក	សៅ	សម	អនុប្រធាន	ការិយាល័យ យុវជន	កំពង់លាវ
១២	លោក	ស្រី	ណារ៉ា	អនុប្រធាន	ការិយាល័យ កីឡា	កំពង់លាវ
១៣	លោក	ម៉ក់	ឈាន	អនុប្រធាន	ការិយាល័យ បឋមសិក្សា	កំពង់លាវ
១៤	លោក	ហឿ	សារិន	នាយករង	វិទ្យាល័យ ព្រះអង្គឌួង	កំពង់លាវ
១៥	លោក	សេង	លី	នាយករង	វិទ្យាល័យ ព្រះអង្គឌួង	កំពង់លាវ
១៦	លោក	ហ៊ី	ស៊ីថា	បង្រៀន	វិទ្យាល័យ ព្រះអង្គឌួង	កំពង់លាវ
១៧	លោក	ព្រុំ	សាគី	នាយករង	គរុកោសល្យ និង វិក្រឹតការខេត្ត	កំពង់លាវ
១៨	លោក	ឡឹក	ធី	អនុប្រធាន	ការិ.អ.យ.ក ស្រុក	ស៊ីធរកណ្តាល
១៩	លោក	គង់	វណ្ណៈ	នាយក	វិទ្យាល័យ ហ៊ុនសែន ព្រែកសណ្តែក	ស៊ីធរកណ្តាល
២០	លោក	សុខ	ធឿន	នាយក	បឋមសិក្សា ពោធិ៍ទី	ស៊ីធរកណ្តាល
២១	លោក	នូវ	ហាយ	បង្រៀន	វិទ្យាល័យ ហ៊ុនសែន ព្រែកសណ្តែក	ស៊ីធរកណ្តាល
២២	លោក	ម៉ក់	ប៊ុនធុន	បង្រៀន	វិទ្យាល័យ ព្រៃដើមថ្នឹង	ស៊ីធរកណ្តាល
២៣	លោក	សន	រ៉េន	បង្រៀន	វិទ្យាល័យ ព្រៃដើមថ្នឹង	ស៊ីធរកណ្តាល
២៤	លោកស្រី	កាន	ស៊ីណែត	បង្រៀន	បឋមសិក្សា ព្រៃដើមថ្នឹង	ស៊ីធរកណ្តាល
២៥	លោកស្រី	ប៉ូច	សារ៉ែន	បង្រៀន	បឋមសិក្សា ស្វាយទាប	ស៊ីធរកណ្តាល
២៦	លោក	សុខ	ថៃម	អនុប្រធាន	ការិ.អ.យ.ក ស្រុក	ពារាំង
២៧	លោក	ផែង	អួន	អនុប្រធាន	ការិ.អ.យ.ក ស្រុក	ពារាំង
២៨	លោក	សេង	សំអឹន	នាយក	បឋមសិក្សា ព្រៃស្រឡិត	ពារាំង
២៩	លោក	ស្រួយ	ស្រ៊ី	នាយក	វិទ្យាល័យ ញឹមវណ្ណដាពារាំង	ពារាំង
៣០	លោក	អ៊ុច	គុន	នាយក	បឋមសិក្សា ស្វាយពល	ពារាំង
៣១	លោក	សែប	សុមេធ	នាយក	បឋមសិក្សា អណ្តូង	ពារាំង
៣២	លោក	ឆាយ	ប៉េងឆាន	នាយករង	វិទ្យាល័យ ព្រៃខ្លៅ	ពារាំង
៣៣	លោក	មួង	សារឿន	នាយក	បឋមសិក្សា ក្រាល	ពារាំង
៣៤	លោក	ឡុង	ចិន្តា	បង្រៀន	អនុវិទ្យាល័យ ព្រៃស្រឡិត	ពារាំង
៣៥	លោក	អ៊ុន	សុផានី	បង្រៀន	វិទ្យាល័យ ញឹមវណ្ណដាពារាំង	ពារាំង
៣៦	លោកស្រី	យ៉ុង	សុដានី	បង្រៀន	បឋមសិក្សា ស្វាយពល	ពារាំង
៣៧	លោកស្រី	ទ្រី	ស៊ីវ៉ូច	បង្រៀន	បឋមសិក្សា ស្វាយពល	ពារាំង
៣៨	លោកស្រី	ឡុង	សុភាព	បង្រៀន	បឋមសិក្សា ស្វាយពល	ពារាំង
៣៩	លោកស្រី	សៅ	សារិន	បង្រៀន	អនុវិទ្យាល័យ កញ្ចំ	ពារាំង

៤០	លោក	យង់	នន	បង្រៀន	បឋមសិក្សា តាំងរលាង	ពារាំង
៤១	លោក	តួច	សាវីន	បង្រៀន	បឋមសិក្សា កំពង់ពពិល	ពារាំង
៤២	លោក	ហែម	ពិសិដ្ឋ	អនុប្រធាន	ការិ.អ.យ.ក ស្រុក	**កំចាយមារ**
៤៣	លោក	សុខ	សារ៉ុម	អនុប្រធាន	ការិ.អ.យ.ក ស្រុក	កំចាយមារ
៤៤	លោក	ទិត	ឈន់លី	អនុប្រធាន	ការិ.អ.យ.ក ស្រុក	កំចាយមារ
៤៥	លោក	កូវ	សុខ	នាយក	វិទ្យាល័យ ជាច	កំចាយមារ
៤៦	លោក	សួរ	វីរ៉ា	នាយក	បឋមសិក្សា ជាច	កំចាយមារ
៤៧	លោកស្រី	ហួត	លាងស្រេង	មន្ត្រី	ការិ.អ.យ.ក ស្រុក	កំចាយមារ
៤៨	លោក	សួ	ប៉ា	មន្ត្រី	ការិ.អ.យ.ក ស្រុក	កំចាយមារ
៤៩	លោក	ហួន	លួត	អនុប្រធាន	ការិ.អ.យ.ក ស្រុក	**កញ្ជ្រៀច**
៥០	លោក	ហ៊ុល	កោសល	នាយករង	អនុវិទ្យាល័យ ស្វាយរមៀត	កញ្ជ្រៀច
៥១	លោក	ឈឹម	ឈឿន	នាយក	បឋមសិក្សា ត្រពាំងថ្នាន់	កញ្ជ្រៀច
៥២	លោក	ឈី	សុខុម	នាយក	បឋមសិក្សា ត្នោត	កញ្ជ្រៀច
៥៣	លោក	យ៉ាន	ជា	នាយក	បឋមសិក្សា កណ្តាច់	កញ្ជ្រៀច
៥៤	លោក	ផុន	ផេន	បង្រៀន	អនុវិទ្យាល័យ គោកថ្នាន់	កញ្ជ្រៀច
៥៥	លោក	ខ្សៅ	ឆៃរ៉ា	បង្រៀន	បឋមសិក្សា ពុទ្ធគយា	កញ្ជ្រៀច
៥៦	លោក	យូ	ស៊ាងហ៊ី	បង្រៀន	បឋមសិក្សា គោកគង់លិច	កញ្ជ្រៀច
៥៧	លោក	យូ	សំអុល	ប្រធាន	ការិ.អ.យ.ក ស្រុក	**ព្រៃវែង**
៥៨	លោក	ទេព	ស៊ីន	នាយក	អនុវិទ្យាល័យ ដីពូន	ព្រៃវែង
៥៩	លោក	ឃុន	វៃ	មន្ត្រី	ការិ.អ.យ.ក ស្រុក	ព្រៃវែង
៦០	លោក	ឡុង	ភន	បង្រៀន	វិទ្យាល័យ ស្វាយអន្ទរ	ព្រៃវែង
៦១	លោក	ជៀប	ផល្លី	បង្រៀន	វិទ្យាល័យ ស្វាយអន្ទរ	ព្រៃវែង
៦២	លោក	ផៃ	សរ	បង្រៀន	បឋមសិក្សា ទឹកថ្លា	ព្រៃវែង
៦៣	លោក	ឈួក	គីមផុង	បង្រៀន	បឋមសិក្សា ចំការក្លួយ	ព្រៃវែង
៦៤	លោកស្រី	ចំរើន	ម៉ាឡៃន	បង្រៀន	បឋមសិក្សា ថ្នល់ជ័យ	ព្រៃវែង
៦៥	លោក	ឈុំ	ឡឿន	បង្រៀន	បឋមសិក្សា ជាខ្លាង	ព្រៃវែង
៦៦	លោកស្រី	សុខ	សឿន	បង្រៀន	បឋមសិក្សា ឥន្ទចក្រី	ព្រៃវែង
៦៧	លោក	ជឹម	ព្រឿន	បង្រៀន	បឋមសិក្សា មេបុណ្យ	ព្រៃវែង
៦៨	លោក	ផង	ស៊ីណា	បង្រៀន	បឋមសិក្សា តងឡុង	ព្រៃវែង
៦៩	លោក	ឌុច	ផឿង	ប្រធាន	ការិ.អ.យ.ក ស្រុក	**កំពង់លាវ**

៧០	លោក	គង់	សំអាត	អនុប្រធាន	ការិ.អ.យ.ក ស្រុក	កំពង់លាវ
៧១	លោក	ហែល	សុរិត	អនុប្រធាន	ការិ.អ.យ.ក ស្រុក	កំពង់លាវ
៧២	លោក	ជា	ជុន	នាយក	អនុវិទ្យាល័យ ព្រែកអន្ទះ	កំពង់លាវ
៧៣	លោក	ប៉ាវ	សុធីរ	បង្រៀន	វិទ្យាល័យ ហ៊ុនសែន កំពង់លាវ	កំពង់លាវ
៧៤	លោក	សៀង	សុផល	បង្រៀន	វិទ្យាល័យ ហ៊ុនសែន កំពង់លាវ	កំពង់លាវ
៧៥	លោក	ជុំ	សម្បត្តិ	នាយករង	បឋមសិក្សា អន្លង់ទ្រា	កំពង់លាវ
៧៦	លោក	ញឹក	សុគណ្ណា	នាយករង	បឋមសិក្សា ព្រែកអន្ទះ	កំពង់លាវ
៧៧	លោក	ហេង	ស៊ីចាន់	បង្រៀន	បឋមសិក្សា ក្តីកណ្តាល	កំពង់លាវ
៧៨	លោកស្រី	ប៉ាវ	សុបញ្ញា	បង្រៀន	បឋមសិក្សា ក្រាំងក្អែក	កំពង់លាវ
៧៩	លោក	ជួន	វឌ្ឍា	បង្រៀន	បឋមសិក្សា បុញ្ញខេត្តារាម	កំពង់លាវ
៨០	លោក	យិន	សុផល	បង្រៀន	បឋមសិក្សា ហ៊ុនសែន បារាយណ៍	កំពង់លាវ
៨១	លោកស្រី	ព្រុំ	គីម	បង្រៀន	បឋមសិក្សា ព្រៃវែងក្រុង	កំពង់លាវ
៨២	លោក	ម៉ៅ	អ៊ី	បង្រៀន	បឋមសិក្សា ស្វាយសុខោ	កំពង់លាវ
៨៣	លោក	ផល	សុភី	បង្រៀន	បឋមសិក្សា រោងដំរី	កំពង់លាវ
៨៤	លោក	ហ៊ុល	សាម៉ន	នាយក	បឋមសិក្សា ត្រពាំងជ្រៃ	មេសាង
៨៥	លោក	ឡេង	សាវុធ	នាយក	វិទ្យាល័យ មេសាង	មេសាង
៨៦	លោក	ជុន	ឈឿន	បង្រៀន	វិទ្យាល័យ មេសាង	មេសាង
៨៧	លោក	តាយ	ម៉ុល្លី	នាយក	បឋមសិក្សា អង្គក្អោត	មេសាង
៨៨	លោក	ហែម	ភឿន	មន្ត្រី	ការិ.អ.យ.ក ស្រុក	មេសាង
៨៩	លោក	ឡុក	អេង	មន្ត្រី	ការិ.អ.យ.ក ស្រុក	មេសាង
៩០	លោក	លីម	សោភ័ណ	មន្ត្រី	ការិ.អ.យ.ក ស្រុក	មេសាង
៩១	លោកស្រី	ម៉ោង	យៀ	បង្រៀន	បឋមសិក្សា សន្ទុង	មេសាង
៩២	លោក	សៅ	សាបាន	បង្រៀន	បឋមសិក្សា ស្វាយជោរ	មេសាង
៩៣	លោក	ព្រឹម	ចន	នាយក	បឋមសិក្សា ចុងទួល	មេសាង
៩៤	លោក	ខឹម	សំអឿន	អនុប្រធាន	ការិ.អ.យ.ក ស្រុក	បាភ្នំ
៩៥	លោក	ប្រាក់	ផល្លី	មន្ត្រី	ការិ.អ.យ.ក ស្រុក	បាភ្នំ
៩៦	លោក	ជូ	សីលា	នាយក	បឋមសិក្សា ឃ្លាំង	បាភ្នំ
៩៧	លោក	វិន	សារឹម	នាយក	បឋមសិក្សា កំរ៉ែង	បាភ្នំ
៩៨	លោក	ម៉េង	សំណាង	នាយករង	បឋមសិក្សា ប្រស្រែ	បាភ្នំ
៩៩	លោក	ជុំ	ស៊ុំ	បង្រៀន	បឋមសិក្សា ព្រេច	បាភ្នំ

១០០	លោក	ឈឹម	សាម៉េត	នាយករង	បឋមសិក្សា ព្រះស្រីសារពេជ្ជ	បាភ្នំ
១០១	លោក	ញឹក	ទិត	នាយក	បឋមសិក្សា ឈើកាច់	បាភ្នំ
១០២	លោក	រតនី	អុល	នាយក	បឋមសិក្សា ពងពស់	បាភ្នំ
១០៣	លោក	ម៉ា	ជឹម	បង្រៀន	វិទ្យាល័យ បាភ្នំ	បាភ្នំ
១០៤	លោក	គុយ	កេន	បង្រៀន	វិទ្យាល័យ ជាស៊ីម រក្សជ័យ	បាភ្នំ
១០៥	លោក	ខុន	ឆុន	នាយក	បឋមសិក្សា ស្ដេហ៍រាន	បាភ្នំ
១០៦	លោក	អ៊ុយ	សុខុម	បង្រៀន	វិទ្យាល័យ បាភ្នំ	បាភ្នំ
១០៧	លោក	អោក	សុផល	បង្រៀន	វិទ្យាល័យ បាភ្នំ	បាភ្នំ
១០៨	លោក	អួង	សុវណ្ណ	បង្រៀន	បឋមសិក្សា ឈើកាច់	បាភ្នំ
១០៩	លោក	គឹម	សុខុម	អនុប្រធាន	ការិ.អ.យ.ក ស្រុក	ព្រះស្ដេច
១១០	លោក	គង់	សោម	នាយក	វិទ្យាល័យ មិត្តភាពខ្មែរ ជប៉ុន	ព្រះស្ដេច
១១១	លោក	ហ៊ឹម	សារឿន	នាយក	បឋមសិក្សា ព្រៃក្ដួច	ព្រះស្ដេច
១១២	លោកស្រី	គង់	គីមលាភ	បង្រៀន	បឋមសិក្សា ព្រៃឡារ	ព្រះស្ដេច
១១៣	លោក	ច័ន្ទ	ឈុំ	នាយក	បឋមសិក្សា ព្រះធំ	ព្រះស្ដេច
១១៤	លោក	គង់	សំអាត	បង្រៀន	បឋមសិក្សា ព្រះអង្គពាន់	ព្រះស្ដេច
១១៥	លោក	ឈឹម	ធុល	នាយក	បឋមសិក្សា បឹងដោល	ព្រះស្ដេច
១១៦	លោកស្រី	រ៉ូ	គា	បង្រៀន	បឋមសិក្សា សម្ដេចឳ-ម៉ែ	ព្រះស្ដេច
១១៧	លោកស្រី	ម៉ី	ចន្ទ្រាស្មី	បង្រៀន	បឋមសិក្សា ពោធិតាគន់	ព្រះស្ដេច
១១៨	លោក	អ៊ុម	សុមេធ	ប្រធាន	ការិ.អ.យ.ក ស្រុក	កំពង់ត្របែក
១១៩	លោក	ថាត់	អួន	អនុប្រធាន	ការិ.អ.យ.ក ស្រុក	កំពង់ត្របែក
១២០	លោក	ហុង	សំអាត	នាយក	អនុវិទ្យាល័យ ជាងដែក	កំពង់ត្របែក
១២១	លោកស្រី	ឃុន	លន់	មន្ត្រី	ការិ.អ.យ.ក ស្រុក	កំពង់ត្របែក
១២២	លោក	ហាស់	ផាន	មន្ត្រី	ការិ.អ.យ.ក ស្រុក	កំពង់ត្របែក
១២៣	លោក	ពុធ	ស៊ីវុត្ថា	នាយក	បឋមសិក្សា ពេជ្ជរតន៍	កំពង់ត្របែក
១២៤	លោក	ជា	សារុន	នាយក	បឋមសិក្សា ត្រើល	កំពង់ត្របែក
១២៥	លោក	ខៀវ	សារ៉ន	នាយក	អនុវិទ្យាល័យ កំពង់ត្របែក	កំពង់ត្របែក
១២៦	លោកស្រី	យស	សុគន្ធ	បង្រៀន	អនុវិទ្យាល័យ ជាងដែក	កំពង់ត្របែក
១២៧	លោកស្រី	ធុយ	សុខា	បង្រៀន	បឋមសិក្សា កំពង់ត្របែក	កំពង់ត្របែក
១២៨	លោកស្រី	គិន	សំយ៉េង	បង្រៀន	បឋមសិក្សា ជ្រៃ	កំពង់ត្របែក
១២៩	លោក	សុខ	ស៊ីថន	បង្រៀន	បឋមសិក្សា ត្រើល	កំពង់ត្របែក

១៣០	លោក	ទិត	សារ៉ាន	បង្រៀន	បឋមសិក្សា ត្រើល	កំពង់ត្របែក
១៣១	លោក	ជា	សំអុល	ប្រធាន	ការិ.អ.យ.ក ស្រុក	ពាមរក៍
១៣២	លោក	សេង	សុខុម	មន្ត្រី	ការិ.អ.យ.ក ស្រុក	ពាមរក៍
១៣៣	លោក	ផាន់	ចន្ថា	មន្ត្រី	ការិ.អ.យ.ក ស្រុក	ពាមរក៍
១៣៤	លោក	ឃុន	នឹម	នាយក	វិទ្យាល័យ ពាមរក៍	ពាមរក៍
១៣៥	លោក	ហ៊ុន	បាន	នាយក	បឋមសិក្សា ពាមរក៍	ពាមរក៍
១៣៦	លោក	មាស	អ៊ាង	នាយក	បឋមសិក្សា ព្រែកល្ពៅង	ពាមរក៍
១៣៧	លោក	វ៉ា	គីម	នាយក	បឋមសិក្សា ព្រែកខ្សាយ "ខ"	ពាមរក៍
១៣៨	លោក	ហេង	ហៃ	នាយក	បឋមសិក្សា ព្រែកអង្គុញ	ពាមរក៍
១៣៩	លោក	ផាន់	ចន្ទី	បង្រៀន	បឋមសិក្សា បន្ទិចប្រាសាទ	ពាមរក៍
១៤០	លោកស្រី	នង	នាង	បង្រៀន	បឋមសិក្សា ពាមរក៍	ពាមរក៍
១៤១	លោក	ថេង	ហ៊ាង	បង្រៀន	បឋមសិក្សា បាបោង	ពាមរក៍
១៤២	លោកស្រី	ប៊ុច	រ៉ានី	បង្រៀន	បឋមសិក្សាប៊ុនរ៉ានីហ៊ុនសែនឧត្តមសមាគម	ពាមរក៍
១៤៣	លោកស្រី	យូរ	សុគុន្ធ	បង្រៀន	បឋមសិក្សា បន្ទិចប្រាសាទ	ពាមរក៍
១៤៤	លោក	ខាត់	សាឃឿន	ប្រធាន	ការិ.អ.យ.ក. ស្រុក	ពាមជរ
១៤៥	លោក	អ៊ី	សារឿន	នាយក	អនុវិទ្យាល័យ កំពង់ប្រាសាទ	ពាមជរ
១៤៦	លោក	ជុន	សុផល	នាយក	បឋមសិក្សា ស្វាយអណ្តូង	ពាមជរ
១៤៧	លោក	ឆាយ	សារិន	នាយក	បឋមសិក្សា អង្គរអង្គ	ពាមជរ
១៤៨	លោកស្រី	សាយ	ហ៊ុន	បង្រៀន	វិទ្យាល័យ រស្មីសាមគ្គី	ពាមជរ
១៤៩	លោក	ហ៊ាប	ហុង	បង្រៀន	បឋមសិក្សា ព្រៃមាន់	ពាមជរ

ខ.មេដាយប្រាក់ការងារ

១	លោកស្រី	វ៉ា	សំអាត	មន្ត្រី	ការិយាល័យ រដ្ឋបាល	កំពង់លាវ
២	លោកស្រី	ឡាច	ភារីយ៉	អនុប្រធាន	ការិយាល័យ អប់រំកុមារតូច	កំពង់លាវ
៣	លោក	កែវ	គឹមណាន	មន្ត្រី	ការិយាល័យ អធិការកិច្ច	កំពង់លាវ
៤	លោក	អៀង	ហ៊ាង	មន្ត្រី	ការិយាល័យ កីឡា	កំពង់លាវ
៥	លោក	ពេជ	សុផល	គណនេយ្យ	វិទ្យាល័យ ព្រះអង្គខ្មួង	កំពង់លាវ
៦	លោក	ស្រស់	វ៉ាមី	លេខា	វិទ្យាល័យ ព្រះអង្គខ្មួង	កំពង់លាវ
៧	លោក	ឆាំ	សុខុម	បង្រៀន	វិទ្យាល័យ ព្រះអង្គខ្មួង	កំពង់លាវ
៨	លោក	សុខ	កែម	បង្រៀន	វិទ្យាល័យ ព្រះអង្គខ្មួង	កំពង់លាវ
៩	លោកស្រី	វ៉ែន	បូរី	បង្រៀន	គរុកោសល្យ និង វិក្រឹតការខេត្ត	កំពង់លាវ

១០	លោកស្រី	គង់	សំអ៊ាន	បង្រៀន	គរុកោសល្យភូមិភាគ ហ៊ុនសែន ព្រៃវែង	កំពង់លាវ
១១	លោក	យុន	យឿន	នាយករង	វិទ្យាល័យ ហ៊ុនសេន ព្រែកសណ្តែក	ស៊ីធរកណ្តាល
១២	លោក	វណ្ណ	លឹមហេង	នាយក	បឋមសិក្សា ព្រៃពោធិ៍	ស៊ីធរកណ្តាល
១៣	លោក	ឈួរ	គឹមស្រ៊ាង	នាយក	បឋមសិក្សា កោងទន្លេ	ស៊ីធរកណ្តាល
១៤	លោក	ស្រង់	សារ៉ុម	នាយក	បឋមសិក្សា ស្វាយទាប	ស៊ីធរកណ្តាល
១៥	លោក	សយ	ធី	បង្រៀន	អនុវិទ្យាល័យ ព្នៅ	ស៊ីធរកណ្តាល
១៦	លោកស្រី	កន	ចន្ថា	បង្រៀន	បឋមសិក្សា ព្រៃដើមថ្នឹង	ស៊ីធរកណ្តាល
១៧	លោកស្រី	នង	ចាន់លី	បង្រៀន	បឋមសិក្សា បាប្រិយ៍	ស៊ីធរកណ្តាល
១៨	លោក	ប៊ី	ប៊ុនឡេង	បង្រៀន	បឋមសិក្សា បាប្រិយ៍	ស៊ីធរកណ្តាល
១៩	លោក	សំ	ភាព	បង្រៀន	បឋមសិក្សា ព្រៃពោធិ៍	ស៊ីធរកណ្តាល
២០	លោក	ជា	បុលលីន	បង្រៀន	បឋមសិក្សា ព្រែកសណ្តែក	ស៊ីធរកណ្តាល
២១	លោក	ឈុំ	ខ្នារ	បង្រៀន	វិទ្យាល័យ ព្រៃដើមថ្នឹង	ស៊ីធរកណ្តាល
២២	លោក	ចៀន	ហួត	បង្រៀន	អនុវិទ្យាល័យហ៊ុនសែន ព្រៃឈើវែង	ស៊ីធរកណ្តាល
២៣	លោក	ជុត	សុផាន	មន្ត្រី	ការិ.អ.យ.ក ស្រុក	ពារាំង
២៤	លោក	ឡៅ	ប៊ុនធី	មន្ត្រី	ការិ.អ.យ.ក ស្រុក	ពារាំង
២៥	លោក	សួន	សាយ	នាយក	អនុវិទ្យាល័យ ព្រៃស្រឡិត	ពារាំង
២៦	លោក	ម៉ៅ	ម៉េង	នាយក	អនុវិទ្យាល័យ មេសរប្រចាន់	ពារាំង
២៧	លោក	គង់	ចក	នាយក	បឋមសិក្សា ទ្រា	ពារាំង
២៨	លោក	អ៊ូ	ប៊ុន	នាយក	អនុវិទ្យាល័យ ព្រែកតាសរ	ពារាំង
២៩	លោក	ទឹម	ជឿន	មន្ត្រី	ការិ.អ.យ.ក ស្រុក	ពារាំង
៣០	លោក	លាស់	លាង	មន្ត្រី	ការិ.អ.យ.ក ស្រុក	ពារាំង
៣១	លោក	ផេង	ម៉ៃ	មន្ត្រី	ការិ.អ.យ.ក ស្រុក	ពារាំង
៣២	លោក	ជុត	ផល	មន្ត្រី	វិទ្យាល័យ ញឹមវណ្ណដាពារាំង	ពារាំង
៣៣	លោក	នៅ	ចន្ថា	មន្ត្រី	វិទ្យាល័យ ហ៊ុនសែន កំពង់ពពិល	ពារាំង
៣៤	លោក	ប្រាក់	ម៉ៅ	មន្ត្រី	បឋមសិក្សា កំពង់ពពិល	ពារាំង
៣៥	លោក	វ៉ាន់	ប៊ុណ្ណា	មន្ត្រី	បឋមសិក្សា កញ្ចំ	ពារាំង
៣៦	លោក	ហេង	ទីណេ	នាយក	អនុវិទ្យាល័យ កំពង់ប្រាំង	ពារាំង
៣៧	លោកស្រី	គល់	វណ្ណហេន	បង្រៀន	បឋមសិក្សា ព្រៃក្រឡាញ់	ពារាំង
៣៨	លោក	សុខ	វិជា	បង្រៀន	បឋមសិក្សា ព្រៃស្លា	ពារាំង
៣៩	លោក	ឱ	ធី	បង្រៀន	វិទ្យាល័យ ហ៊ុនសែន កំពង់ពពិល	ពារាំង

៤០	លោក	ហ៊ុយ	ឆាយ	បង្រៀន	អនុវិទ្យាល័យ កំពង់ត្រាំង	ពារាំង
៤១	លោកស្រី	តៃ	សៀកលីវ	បង្រៀន	បឋមសិក្សា ស្វាយពល	ពារាំង
៤២	លោក	ឈួន	ណាំហេង	បង្រៀន	វិទ្យាល័យ ញ៉ឹមវណ្ណដា ពារាំង	ពារាំង
៤៣	លោក	បៃន	សំណាង	បង្រៀន	អនុវិទ្យាល័យ ព្រៃកតាសរ	ពារាំង
៤៤	លោកស្រី	ចេង	សុខេង	បង្រៀន	អនុវិទ្យាល័យ កំពង់ឫស្សី	ពារាំង
៤៥	លោក	ជ័យ	សុផល	បង្រៀន	អនុវិទ្យាល័យ កញ្ចំ	ពារាំង
៤៦	លោក	មុំ	ធីរិទ្ធ	បង្រៀន	វិទ្យាល័យ ព្រៃញ្ញៅ	ពារាំង
៤៧	លោក	ចាន់	សុភាព	បង្រៀន	អនុវិទ្យាល័យ ព្រៃស្នៀត	ពារាំង
៤៨	លោកស្រី	ផ្លុង	សារឿន	បង្រៀន	បឋមសិក្សា ពាមអំពិល	ពារាំង
៤៩	លោក	សុខ	យឿង	បង្រៀន	អនុវិទ្យាល័យ រាប	ពារាំង
៥០	លោក	ហាង	ចន្ថា	មន្ត្រី	ការិ.អ.យ.ក ស្រុក	កំចាយមារ
៥១	លោក	សៅ	បូទុម្ព	នាយក	បឋមសិក្សា ស្មោង	កំចាយមារ
៥២	លោក	សួន	សាមាន	នាយក	បឋមសិក្សា ជោរី	កំចាយមារ
៥៣	លោក	សុន	សយ	នាយករង	បឋមសិក្សា ក្រពៅចាស់	កំចាយមារ
៥៤	លោកស្រី	គង់	ហែមកា	មន្ត្រី	ការិ.អ.យ.ក ស្រុក	កំចាយមារ
៥៥	លោក	ចិន	សុផលី	នាយក	វិទ្យាល័យ កំចាយមារ	កំចាយមារ
៥៦	លោក	បេ	លំអាន	នាយក	អនុវិទ្យាល័យ ព្រៃធំ	កំចាយមារ
៥៧	លោក	សំ	មឿន	នាយក	បឋមសិក្សា ក្រពៅថ្មី	កំចាយមារ
៥៨	លោក	វ៉ា	សុត	នាយករង	បឋមសិក្សា ចំការចេក	កំចាយមារ
៥៩	លោក	ឥន	សារឿន	នាយករង	បឋមសិក្សា ស្មោង	កំចាយមារ
៦០	លោក	ពេជ	ចែម	នាយករង	បឋមសិក្សា ក្រពៅថ្មី	កំចាយមារ
៦១	លោក	ធិន	សើរី	នាយករង	បឋមសិក្សា ជាច	កំចាយមារ
៦២	លោក	អេង	បាន	នាយករង	អនុវិទ្យាល័យ ច្រេស	កំចាយមារ
៦៣	លោក	ជាម	សុវណ្ណថុន	បង្រៀន	វិទ្យាល័យ ព្រះបាទនរោត្តម	កញ្ជ្រៀច
៦៤	លោក	ជឹម	ជ័យ	បង្រៀន	អនុវិទ្យាល័យ គោកគង់កើត	កញ្ជ្រៀច
៦៥	លោក	អ៊ាង	ម៉ូលីកា	បង្រៀន	អនុវិទ្យាល័យ គោកថ្កាន់	កញ្ជ្រៀច
៦៦	លោក	ពោន	សារី	មន្ត្រី	ការិ.អ.យ.ក ស្រុក	កញ្ជ្រៀច
៦៧	លោកស្រី	ហ៊ីង	សារ៉ុម	មន្ត្រី	ការិ.អ.យ.ក ស្រុក	កញ្ជ្រៀច
៦៨	លោក	រី	ឌីណា	បង្រៀន	អនុវិទ្យាល័យ ត្នោត	កញ្ជ្រៀច
៦៩	លោក	ប៉ែន	ខេង	នាយក	បឋមសិក្សា ពោធិស្រែ	កញ្ជ្រៀច

៧០	លោក	ដុល	ធិន	បង្រៀន	បឋមសិក្សា ឧត្តមប្រឹក្សា	កញ្ជ្រៀច
៧១	លោក	ភុន	ថៃ	នាយក	បឋមសិក្សា ចុងអំពិល	កញ្ជ្រៀច
៧២	លោក	ពែក	ប៉ៃ	លេខា	បឋមសិក្សា ក្បាលដំរី	កញ្ជ្រៀច
៧៣	លោក	គុយ	អ៊ីម	បង្រៀន	បឋមសិក្សា ត្នោត	កញ្ជ្រៀច
៧៤	លោក	សូ	សារី	នាយក	បឋមសិក្សា ធម្មកេរ្តិ៍	កញ្ជ្រៀច
៧៥	លោក	សន	ស៊ីណា	បង្រៀន	បឋមសិក្សា ពោធិទង	កញ្ជ្រៀច
៧៦	លោក	មឿង	ពិសី	បង្រៀន	អនុវិទ្យាល័យ គោកគង់លិច	កញ្ជ្រៀច
៧៧	លោក	ឡឹក	ណាំគី	នាយក	បឋមសិក្សា ពុទ្ធគយា	កញ្ជ្រៀច
៧៨	លោក	មាស	ផែង	នាយករង	វិទ្យាល័យ ស្វាយអន្ទរ	ព្រៃវែង
៧៩	លោក	ប៊ុត	ហ៊ួន	នាយក	អនុវិទ្យាល័យ ពានរោង	ព្រៃវែង
៨០	លោក	វង់	សារិន	នាយក	បឋមសិក្សា ខ្សោក	ព្រៃវែង
៨១	លោក	ព្រុំ	សុផល	នាយក	បឋមសិក្សា មេបុណ្យ	ព្រៃវែង
៨២	លោក	កែវ	ហ៊ីម	នាយក	បឋមសិក្សា សិរីមង្គល	ព្រៃវែង
៨៣	លោក	ចាន់	ឆន	នាយករង	បឋមសិក្សា ឥន្ទចក្រី	ព្រៃវែង
៨៤	លោក	សំ	សារឿន	មន្ត្រី	ការិ.អ.យ.ក ស្រុក	ព្រៃវែង
៨៥	លោកស្រី	ញួង	ផល្លីន	បណ្ណារក្ស	បឋមសិក្សា ស្វាយអន្ទរ	ព្រៃវែង
៨៦	លោក	ផង់	ហឿន	បណ្ណារក្ស	បឋមសិក្សា ព្រៃខ្លា	ព្រៃវែង
៨៧	លោក	ភឹម	ស្រ៊ន់	បង្រៀន	បឋមសិក្សា ព្រៃជ្រាំង	ព្រៃវែង
៨៨	លោក	ចាន់	យឹន	បង្រៀន	បឋមសិក្សា បាក់តាង	ព្រៃវែង
៨៩	លោកស្រី	តូច	សុភាព	បង្រៀន	បឋមសិក្សា ថ្នាវ	ព្រៃវែង
៩០	លោកស្រី	ទូច	ចាន់ថុល	បង្រៀន	បឋមសិក្សា ខ្សោក	ព្រៃវែង
៩១	លោក	ទន់	ណារិទ្ធ	បង្រៀន	វិទ្យាល័យ ស្វាយអន្ទរ	ព្រៃវែង
៩២	លោក	សារឿន	ពន្លឺ	បង្រៀន	បឋមសិក្សា ជាខ្លាង	ព្រៃវែង
៩៣	លោកស្រី	ជា	សុធារ៉ា	បង្រៀន	បឋមសិក្សា ថ្នល់ជ័យ	ព្រៃវែង
៩៤	លោក	អ៊ិត	ផាន់	បង្រៀន	វិទ្យាល័យ ស្វាយអន្ទរ	ព្រៃវែង
៩៥	លោក	លី	សុផាត	បង្រៀន	អនុវិទ្យាល័យ ទឹកថ្លា	ព្រៃវែង
៩៦	លោក	ឌុយ	សូដា	បង្រៀន	វិទ្យាល័យ ស្វាយអន្ទរ	ព្រៃវែង
៩៧	លោក	ម៉ៅ	សារិ	មន្ត្រី	ការិ.អ.យ.ក ស្រុក	កំពង់លាវ
៩៨	លោក	អេង	វិបុល	មន្ត្រី	ការិ.អ.យ.ក ស្រុក	កំពង់លាវ
៩៩	លោកស្រី	ស៊ុន	ហ៊ាន	មន្ត្រី	ការិ.អ.យ.ក ស្រុក	កំពង់លាវ

១០០	លោកស្រី	នៅ	សុកញ្ញា	មន្ត្រី	ការិ.អ.យ.ក ស្រុក	កំពង់លាវ
១០១	លោក	ម៉ៅ	ប៊ុនសេង	នាយករង	វិទ្យាល័យ ហ៊ុនសែន កំពង់លាវ	កំពង់លាវ
១០២	លោកស្រី	គ្រៀល	ដារិទ្ធ	បង្រៀន	វិទ្យាល័យ ហ៊ុនសែន កំពង់លាវ	កំពង់លាវ
១០៣	លោក	ចាន់	រឿង	នាយក	បឋមសិក្សា ហ៊ុនសែន បារាយណ៍	កំពង់លាវ
១០៤	លោក	ម៉ម	គីណាត	នាយក	បឋមសិក្សា អន្លង់ទ្រា	កំពង់លាវ
១០៥	លោក	នៅ	ហុងស្រេង	នាយក	បឋមសិក្សា តាកោ	កំពង់លាវ
១០៦	លោក	សំ	សុផល	នាយក	បឋមសិក្សា ព្រៃកអន្ទះ	កំពង់លាវ
១០៧	លោក	រិន	ពឿន	នាយក	បឋមសិក្សា ក្រាំងក្អែក	កំពង់លាវ
១០៨	លោក	សំ	សុផន	នាយក	បឋមសិក្សា ព្រែកថ្លាំ	កំពង់លាវ
១០៩	លោកស្រី	ឃុត	សាខន	បង្រៀន	បឋមសិក្សា ក្តីកណ្តាល	កំពង់លាវ
១១០	លោកស្រី	ភៀន	សុធាន	បង្រៀន	បឋមសិក្សា ក្តីកណ្តាល	កំពង់លាវ
